ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស

## ស្តីពី

# គោលការណ៍ណែនាំនីតិវិធី និងដំណើរការរៀបចំ សហគមន៍តំបន់ការពារធម្មជាតិ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងបរិស្ថាន**

លេខ.....................ប.ស្ក .កអជ

# ប្រកាស

# ស្តីពី

# គោលការណ៍ណែនាំនីតិវិធី និងដំណើរការរៀបចំ សហគមន៍តំបន់ការពារធម្មជាតិ

# រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ធម្មនុញ្ញ បន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រិត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន។

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១. –**

ប្រកាសនេះមានគោលដៅកំណត់វិធាននៃការបង្កើតការគ្រប់គ្រងនិងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលមានគោលបំណង ៖

- អនុវត្តន៍ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ លិខិតបទដ្ឋានច្បាប់ផ្សេងៗដែលទាក់ទងនឹងការគ្រប់គ្រងនិងការប្រើប្រាស់ធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន
- កំណត់សិទ្ធិ តួនាទី ការទទួលខុសត្រូវរបស់ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ សហគមន៍តំបន់ការពារធម្មជាតិ នាយកតំបន់ការពារធម្មជាតិ មន្ទីរបរិស្ថាន ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដែលចូលរួមគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
- ផ្តល់សិទ្ធិដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ចូលរួមក្នុងការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ក្នុងការគ្រប់គ្រង ប្រើប្រាស់ធនធានធម្មជាតិនិងទទួលផលប្រយោជន៍ពីធនធានធម្មជាតិ ដើម្បីរួមចំណែកធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅដោយរក្សាបាននូវ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ ជំនឿ សាសនា ស្របតាមកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិ
- ផ្តល់ក្របខណ្ឌច្បាប់សម្រាប់បង្កលក្ខណៈងាយស្រួលដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្នុងការរៀបចំសហគមន៍តំបន់ការពារធម្មជាតិដើម្បីរួមចំណែកក្នុងការចូលរួមគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិ ព្រមទាំងជីវៈចម្រុះប្រកបដោយនិរន្តរភាព
- អនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចតាមរយៈការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

- ផ្តល់លទ្ធភាពដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច យល់ដឹងកាន់តែច្បាស់ពីសារៈប្រយោជន៍នៃធនធានធម្មជាតិ តាមរយៈការចូលរួមគ្រប់គ្រងប្រើប្រាស់ និងការពារធនធានធម្មជាតិដោយផ្ទាល់។

**ប្រការ ២. –**

សហគមន៍តំបន់ការពារធម្មជាតិ អាចរៀបចំនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ឬ តំបន់សហគមន៍។

**ប្រការ ៣. –**

សហគមន៍តំបន់ការពារធម្មជាតិ ដែលបានរៀបចំកន្លងមក ត្រូវធ្វើការកែសម្រួល និង បំពេញបន្ថែមឱ្យស្របទៅតាមគោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**ប្រការ ៤. –**

អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ជាសេនាធិការឱ្យក្រសួងបរិស្ថានមានភារកិច្ច ៖

- សម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងសហគមន៍តំបន់ការពារធម្មជាតិ
- លើកសំណើដាក់ជូនក្រសួងបរិស្ថាន ក្នុងការចេញប្រកាសទទួលស្គាល់ បដិសេធ ឬ បញ្ឈប់ដំណើរការអនុវត្តសហគមន៍តំបន់ការពារធម្មជាតិ ដែលមិនអនុវត្តតាមកិច្ចព្រមព្រៀង
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការគាំទ្រដល់ការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ
- សម្របសម្រួលនិងធ្វើអន្តរាគមន៍ដោះស្រាយទំនាស់ នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ

**ប្រការ ៥. –**

នាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ ជាសេនាធិការឱ្យអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ មានភារកិច្ច ៖

- សិក្សាស្រាវជ្រាវពីលទ្ធភាព និងវាយតម្លៃក្នុងការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ តាមរយៈរដ្ឋបាលតំបន់ការពារធម្មជាតិថ្នាក់មូលដ្ឋាន និងចងក្រងឯកសារ
- រៀបចំលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ
- ពិនិត្យនិងផ្តល់យោបល់លើ កិច្ចព្រមព្រៀងស្តីពី ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិជាមួយសហគមន៍មូលដ្ឋាន
- ពិនិត្យនិងផ្តល់យោបល់លើលក្ខន្តិកៈ និងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
- ផ្តល់ការគាំទ្រសេវាបណ្តុះបណ្តាលដល់ក្រុមការងារសម្របសម្រួល និងគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ
- ផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងសហគមន៍តំបន់ការពារធម្មជាតិ
- សម្របសម្រួលដោះស្រាយបញ្ហា នៅពេលមានការស្នើឡើងពីសហគមន៍តំបន់ការពារធម្មជាតិ
- ត្រួតពិនិត្យ និងវាយតម្លៃ លើដំណើរការអនុវត្តន៍សហគមន៍តំបន់ការពារធម្មជាតិ ការអនុវត្តកិច្ចព្រមព្រៀង
និងការអនុវត្តផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។

## ប្រការ ៦. –

មន្ទីរបរិស្ថានមានភារកិច្ច និងទទួលខុសត្រូវ ដូចខាងក្រោម ៖

- សហការជាមួយអាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ដើម្បីសម្របសម្រួលក្នុងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ
- សហការជាមួយអាជ្ញាធរដែនដី ក្នុងការសម្របសម្រួលដោះស្រាយទំនាស់ដែលកើតមាននៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ
- បណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយ នូវរាល់គោលការណ៍និងព័ត៌មានផ្សេងៗដែលពាក់ព័ន្ធទៅនឹងសហគមន៍តំបន់ការពារធម្មជាតិ
- ចូលរួមត្រួតពិនិត្យនិងវាយតម្លៃ លើការអនុវត្តផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

- ធ្វើរបាយការណ៍ត្រីមាស ស្តីពី វឌ្ឍនភាពរបស់សហគមន៍តំបន់ការពារធម្មជាតិ ជូនក្រសួងបរិស្ថាន។

**ប្រការ ៧. –**

នាយកតំបន់ការពារធម្មជាតិ មានភារកិច្ច និងទទួលខុសត្រូវ ដូចខាងក្រោមៈ

- ធ្វើបច្ចុប្បន្នភាពសហគមន៍តំបន់ការពារធម្មជាតិឱ្យស្របតាមច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ និងគោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ
- ចូលរួមសិក្សាវាយតម្លៃពីសក្តានុពលនៃការបង្កើត និងការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ
- អប់រំ ផ្សព្វផ្សាយ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ
- ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើសកម្មភាពអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ
- សហការជាមួយ អាជ្ញាធរដែនដី ក្នុងការសម្របសម្រួលដោះស្រាយទំនាស់ ដែលកើតមាននៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ
- គាំទ្រគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ក្នុងការទប់ស្កាត់បទល្មើសលើធនធានធម្មជាតិ
- ធ្វើរបាយការណ៍ត្រីមាសស្តីពីវឌ្ឍនភាពសហគមន៍តំបន់ការពារធម្មជាតិ ជូនមន្ទីរបរិស្ថាន ក្នុងករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់។

## ជំពូកទី៣
## ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ

**ប្រការ ៨. –**

សហគមន៍តំបន់ការពារធម្មជាតិ ជានីតិបុគ្គលមួយក្រុមមានសញ្ជាតិជាខ្មែរ ដែលរស់នៅក្នុងឬក្បែរតំបន់ការពារធម្មជាតិ ត្រូវបានរៀបចំឡើងដោយការស្ម័គ្រចិត្ត ក្នុងគោលបំណងថែរក្សាធនធានធម្មជាតិ ប្រពៃណី ទំនៀមទំលាប់ ជំនឿ និងសាសនា សំដៅបង្កើនជីវភាពរស់នៅតាមរយៈការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

**ប្រការ ៩. –**

សហគមន៍តំបន់ការពារធម្មជាតិ មានគោលដៅធ្វើឱ្យប្រសើរឡើងនូវ ធនធានធម្មជាតិ និងជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ស្របតាមស្ថានភាពជាក់ស្តែងនៃធនធានធម្មជាតិនៅក្នុងសហគមន៍នីមួយៗ ដូចជា៖ ការគ្រប់គ្រងផ្តោតទៅលើ ធនធានជលផល ធនធានព្រៃឈើ អេកូរទេសចរណ៍ ការគ្រប់គ្រងទីជម្រាល ការប្រើប្រាស់ទឹក និងការប្រើប្រាស់ដីធ្លីនៅ ក្នុងតំបន់ការពារធម្មជាតិ។

**ប្រការ ១០. –**

ការស្នើសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើឡើងតាមរយៈមេឃុំ ចៅសង្កាត់ នាយកតំបន់ការពារធម្មជាតិ អភិបាលស្រុក/ក្រុង ប្រធានមន្ទីរបរិស្ថាន អភិបាលខេត្ត និងមានការសម្រេចពីក្រសួងបរិស្ថាន។ ការចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើឡើងជាលក្ខណៈគ្រួសារ។ ទម្រង់គំរូនៃពាក្យសុំបង្កើតមានចែងក្នុងឧបសម្ព័ន្ធទី២។

**ប្រការ ១១. –**

សហគមន៍តំបន់ការពារធម្មជាតិ អាចរៀបចំបានលុះត្រាតែមានចំនួនគ្រួសារស្ម័គ្រចិត្តចូលរួមចាប់ពី៦០% (ហុកសិបភាគរយ) នៃគ្រួសារសរុបក្នុងភូមិដែលបានចូលរួម។

**ប្រការ ១២. –**

សហគមន៍តំបន់ការពារធម្មជាតិ ត្រូវមាន៖ ពាក្យស្នើសុំជាសមាជិក ពាក្យស្នើសុំបង្កើតមានលក្ខន្តិកៈ មានប្រកាសទទួលស្គាល់ពីក្រសួងបរិស្ថាន កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ និងស្របទៅតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

## ជំពូកទី៤
## ការរៀបចំគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ

**ប្រការ ១៣. –**

សហគមន៍តំបន់ការពារធម្មជាតិនីមួយៗ ត្រូវដឹកនាំ និងគ្រប់គ្រងដោយគណៈកម្មការមានឈ្មោះថា "គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ........"។ គណៈកម្មការនេះត្រូវជ្រើសរើសឡើងដោយការបោះឆ្នោតសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្ត្រីត្រូវបានលើកទឹកចិត្តឱ្យ

ចូលរួមក្នុងគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ។ របៀបនៃការបោះឆ្នោតមានចែងក្នុងនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ។

**ប្រការ ១៤. –**

សមាជិកសហគមន៍ទាំងពីរភេទ មានសិទ្ធិឈរឈ្មោះជាបេក្ខជនគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ដោយមានលក្ខខណ្ឌដូចខាងក្រោម៖

- ជាសមាជិកនៃសហគមន៍តំបន់ការពារធម្មជាតិ
- មានសញ្ជាតិខ្មែរពីកំណើត
- មានលក្ខណៈសម្បត្តិសមស្រប ដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ។

**ប្រការ ១៥. –**

តំណាងគ្រួសារដែលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ មានសិទ្ធិចូលរួមបោះឆ្នោតជ្រើសរើសគណៈកម្មការបានលុះត្រាតែមានអាយុដប់ប្រាំបី(១៨) ឆ្នាំឡើង។ ការបោះឆ្នោតយកជាផ្លូវការបាន លុះត្រាតែមានការចូលរួមយ៉ាងតិចបំផុតហុកសិបភាគរយ(៦០%) នៃចំនួនគ្រួសារដែលជាសមាជិកសហគមន៍។

**ប្រការ ១៦. –**

ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានការចូលរួមសង្កេតការណ៍ពីក្រុមប្រឹក្សាឃុំ សង្កាត់ និងនាយកតំបន់ការពារធម្មជាតិ។ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានដីការទទួលស្គាល់ពីមេឃុំ ចៅសង្កាត់ ក្រោយពេលប្រកាសទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតជាផ្លូវការក្នុងរយៈពេល(១៥)ដប់ប្រាំថ្ងៃ។ បន្ទាប់ពីមេឃុំ ចៅសង្កាត់ ចេញដីការទទួលស្គាល់ជាផ្លូវការ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវដឹកនាំការងារនិងគ្រប់គ្រងក្នុងសហគមន៍នោះ។

**ប្រការ ១៧. –**

ក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិចេញសេចក្តីសម្រេចកែសម្រួលសមាសភាពគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ដែលអនុវត្តផ្ទុយពីលក្ខន្តិកៈរបស់សហគមន៍ ដោយផ្អែកតាមសំណើរបស់សមាជិកសហគមន៍ចាប់ពីហុកសិបភាគរយ(៦០%)ឡើងទៅ។

**ប្រការ ១៨. –**

គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិមានអណត្តិប្រាំ(៥)ឆ្នាំ ហើយផុតកំណត់ក្រោយពេលគណៈកម្មការថ្មីចូលបំពេញការងារ។ ករណីសមាជិកគណៈកម្មការ មានភាពអសកម្មឬលាលែងពីជួរគណៈកម្មការ ត្រូវជ្រើសរើសបេក្ខជនដែលមានសម្លេងឆ្នោតបន្ទាប់មកជំនួស ឬធ្វើការបោះឆ្នោតជាលក្ខណៈពិសេស ដោយមានការឯកភាពពីសមាជិកសហគមន៍ហុកសិបភាគរយ(៦០%)ឡើងទៅ។ សិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ មានចែងក្នុងប្រការ២១ នៃប្រកាសនេះ។

## ជំពូកទី៥
## សិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់
## សហគមន៍តំបន់ការពារធម្មជាតិ

**ប្រការ ១៩. –**

សហគមន៍តំបន់ការពារធម្មជាតិមានសិទ្ធិ តួនាទី និងការទទួលខុសត្រូវដូចខាងក្រោមៈ

- ចូលរួមគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិស្របតាមលក្ខន្តិកៈ និងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
- រៀបចំលក្ខន្តិកៈ ផែនការគ្រប់គ្រងនិងកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិឱ្យស្របទៅតាមច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ ប្រកាសស្តីពីគោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ
- អនុវត្តលក្ខន្តិកៈ ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិ
- សហការជាមួយស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ។

**ប្រការ ២០. –**

សហគមន៍តំបន់ការពារធម្មជាតិពុំមានសិទ្ធិៈ

- បែងចែកធ្វើជាកម្មសិទ្ធិឯកជន លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បញ្ចាំ វិនិយោគ ឬផ្ទេរដីព្រៃសហគមន៍តំបន់ការពារធម្មជាតិ ដែលបានប្រគល់ឱ្យក្នុងកិច្ចព្រមព្រៀងទៅភាគីផ្សេងទៀតបានឡើយទោះបីក្នុងរូបភាពណាក៏ដោយ

- ប្រើប្រាស់ធនធានធម្មជាតិនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ ខុសពីផែនការគ្រប់គ្រង។

**ប្រការ ២១. –**

គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិមានសិទ្ធិ តួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ជាតំណាងសហគមន៍តំបន់ការពារធម្មជាតិ មានសិទ្ធិធ្វើសេចក្តីសម្រេចចិត្ត ដោយឈរលើមតិភាគច្រើន
- ទំនាក់ទំនងនិងសហការជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង
- ចូលរួមនិងសម្របសម្រួល ក្នុងការកំណត់ទីតាំង ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ
- ដឹកនាំរៀបចំលក្ខន្តិកៈ ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិ ឱ្យស្របទៅតាមគោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ
- ជាតំណាងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីចុះកិច្ចព្រមព្រៀង ស្តីពី ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន
- អប់រំ ផ្សព្វផ្សាយ ដល់សមាជិកសហគមន៍អំពីការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាព
- ជាតំណាងសហគមន៍តំបន់ការពារធម្មជាតិ ក្នុងការសម្របសម្រួលដោះស្រាយទំនាស់លើការប្រើប្រាស់ធនធានធម្មជាតិ
- ត្រួតពិនិត្យ និងវាយតម្លៃ ដោយមានការចូលរួមពីសមាជិកសហគមន៍ លើសកម្មភាពអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ
- ធានាការបែងចែកផលប្រយោជន៍ក្នុងសហគមន៍ប្រកបដោយតម្លាភាពនិងសមធម៌
- ធ្វើសេចក្តីសម្រេចក្នុងការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ ដោយមានការយល់ព្រមពីសមាជិកភាគច្រើន ស្របតាមលក្ខន្តិកៈ ផែនការគ្រប់គ្រង និងកិច្ចព្រម

ព្រៀងសហគមន៍តំបន់ការពារធម្មជាតិ

- រៀបចំរបាយការណ៍ប្រចាំត្រីមាស ជូននាយកតំបន់ការពារធម្មជាតិ ដោយចម្លងជូនក្រុមប្រឹក្សាឃុំ/សង្កាត់ និងអាជ្ញាធរស្រុក/ក្រុង ក្នុងករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់
- តួនាទីផ្សេងទៀត ត្រូវបានចែងនៅក្នុងលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិស្របទៅតាមស្ថានភាពជាក់ស្តែងក្នុងតំបន់នីមួយៗ។

## ជំពូកទី៦
## លក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ

### ប្រការ ២២. –

សហគមន៍តំបន់ការពារធម្មជាតិ ត្រូវរៀបចំលក្ខន្តិកៈសម្រាប់ការគ្រប់គ្រងសហគមន៍ ដោយមានការជួយសម្របសម្រួលពីនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ មន្ទីរបរិស្ថាន នាយកតំបន់ការពារធម្មជាតិ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងដៃគូអភិវឌ្ឍន៍។

### ប្រការ ២៣. –

លក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានការចុះហត្ថលេខាទទួលស្គាល់ពីមេឃុំ/ចៅសង្កាត់ នាយកតំបន់ការពារធម្មជាតិ អភិបាលស្រុក/ក្រុង ប្រធានមន្ទីរបរិស្ថាន និងអភិបាលខេត្ត។

### ប្រការ ២៤. –

លក្ខន្តិកៈសហគមន៍ អាចកែសម្រួលបាន នៅពេលមានសំណូមពរ និងមានការឯកភាពពីសមាជិកសហគមន៍ ចំនួនពីហុកសិបភាគរយ (៦០%)ឡើងទៅ។

## ជំពូកទី៧
## ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

### ប្រការ ២៥. –

គណៈកម្មការនិងសមាជិកសហគមន៍តំបន់ការពារធម្មជាតិ ត្រូវចូលរួមរៀបចំផែនការ

គ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដោយអាចស្នើសុំការជួយសម្របសម្រួលនិងគាំទ្របច្ចេកទេស សម្ភារៈ ពីនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ មន្ទីរបរិស្ថាន នាយកតំបន់ការពារធម្មជាតិនិងដៃគូអភិវឌ្ឍន៍ ។

**ប្រការ ២៦. –**

ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ មានសុពលភាពរយៈពេលប្រាំ(៥) និងធ្វើសមាហរណកម្មជាមួយផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ឃុំ សង្កាត់។ របៀបនៃការរៀបចំផែនការគ្រប់គ្រង មានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ។

**ប្រការ ២៧. –**

ប្រភពថវិកាសម្រាប់គាំទ្រការអនុវត្តផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិបានមកពី៖

- ប្រាក់សំណងការខូចខាត
- ប្រាក់ភាគទានប្រចាំខែរបស់សមាជិកសហគមន៍
- ប្រាក់បានមកពីអ្នកចាប់អារម្មណ៍ សប្បុរសជន និងដៃគូអភិវឌ្ឍន៍
- ប្រាក់ចំណូលពីការលក់អនុផលព្រៃឈើ
- ប្រាក់ចំណូលពីសេវាអេកូទេសចរណ៍
- ប្រាក់មូលនិធិរដេបូក
- មូលនិធិឃុំ/សង្កាត់ និង
- មូលនិធិផ្សេងៗទៀត។

**ប្រការ ២៨. –**

នាយកតំបន់ការពារធម្មជាតិ និងមន្ទីរបរិស្ថាន ត្រូវត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ជារៀងរាល់ឆ្នាំ ឬមុនពេលកំណត់ក្នុងករណីចាំបាច់។ នាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើការពិនិត្យ និងវាយតម្លៃការអនុវត្តផែនការគ្រប់គ្រងជារៀងរាល់បី(៣)ឆ្នាំម្តង ឬក៏មុនពេលកំណត់ក្នុងករណីចាំបាច់។ ការត្រួតពិនិត្យ និងវាយតម្លៃ ត្រូវធ្វើឡើងដោយមានការចូលរួមពីសហគមន៍តំបន់ការពារធម្មជាតិ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងដៃគូអភិវឌ្ឍន៍។

**ប្រការ ២៩. –**

ការរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវចាប់ផ្តើមរៀបចំបន្ទាប់ពីមានការទទួលស្គាល់លើលក្ខន្តិកៈសហគមន៍។ ដំណើរការរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិមិនឱ្យលើសពីមួយ(១)ឆ្នាំ។

**ប្រការ ៣០. –**

ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានការចុះហត្ថលេខាទទួលស្គាល់ពីមេឃុំ/ចៅសង្កាត់ នាយកតំបន់ការពារធម្មជាតិ អភិបាលស្រុក/ក្រុង មន្ទីរបរិស្ថាន និងអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ។

## ជំពូកទី៨
## កិច្ចព្រមព្រៀង ស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

**ប្រការ ៣១. –**

សហគមន៍ត្រូវរៀបចំកិច្ចព្រមព្រៀង ស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ។ របៀបនៃការរៀបចំមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ។

**ប្រការ ៣២. –**

កិច្ចព្រមព្រៀងស្តីពី ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានភ្ជាប់ឯកសារមកជាមួយ ដូចជា៖

- ពាក្យស្នើសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិ
- ប្រកាសទទួលស្គាល់ពី ក្រសួងបរិស្ថាន
- លក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ
- ផែនទីសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានមាត្រដ្ឋានច្បាស់លាស់ និងមានការទទួលស្គាល់ជាផ្លូវការ
- ដីការទទួលស្គាល់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិពីមេឃុំ/ចៅសង្កាត់
- ឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងករណីចាំបាច់។

**ប្រការ ៣៣. –**

ប្រធានគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ មានសិទ្ធិចុះកិច្ចព្រមព្រៀង ស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ជាមួយនឹង អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ។ កិច្ចព្រមព្រៀងនេះ មានសុពលភាពរយៈពេលដប់ប្រាំ(១៥)ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា។ ក្នុងរយៈពេលប្រាំមួយ(៦)ខែ មុនកិច្ចព្រមព្រៀងផុតសុពលភាព គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើសំណើជាលាយល័ក្ខអក្សរមកអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ដើម្បីបន្តកិច្ចព្រមព្រៀងថ្មី។

**ប្រការ ៣៤. –**

កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ អាចធ្វើការកែសម្រួលដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- លទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តដែលតម្រូវឱ្យមានការកែសម្រួល
- ការឯកភាពគ្នារវាងភាគីទាំងពីរជាលាយលក្ខណ៍អក្សរ ដោយមានការឯកភាពពីរភាគបី (២/៣)ពីសមាជិកសហគមន៍។

**ប្រការ ៣៥. –**

កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ អាចលុបមុនពេលកំណត់ ដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- លទ្ធផលនៃការត្រួតពិនិត្យនិងវាយតម្លៃដែលមានចែងក្នុងកិច្ចព្រមព្រៀងនិងផែនការគ្រប់គ្រងរបស់សហគមន៍
- អនុវត្តផ្ទុយពីកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
- លទ្ធផលនៃការសិក្សារបស់រាជរដ្ឋាភិបាល បង្ហាញថាតំបន់នោះផ្តល់ផលប្រយោជន៍ជាសាធារណៈនិងសង្គមច្រើនជាងសហគមន៍តំបន់ការពារធម្មជាតិ។ ក្នុងករណីនេះអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នឹងជូនដំណឹងជាលាយល័ក្ខអក្សរ ទៅសហគមន៍តំបន់ការពារធម្មជាតិ ក្នុងរយៈពេលប្រាំមួយ(៦)ខែមុនការលុប។ សហគមន៍ត្រូវទទួលបានការលើកទឹកចិត្ត និងទទួលផលប្រយោជន៍ពីគម្រោងអភិវឌ្ឍន៍នោះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**ប្រការ ៣៦. –**

អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ខុទ្ទការល័យរដ្ឋមន្ត្រី អគារធិការដ្ឋាន មន្ទីរបរិស្ថាន នាយកតំបន់ការពារធម្មជាតិ អង្គភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវសហការអនុវត្តសេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**<u>កន្លែងទទួលៈ</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- គ្រប់អភិបាលរាជធានី ខេត្ត
- ដូចប្រការ ៣៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# នីតិវិធី
# ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

# ជំហានទី ១
# ការសិក្សាដោយមានការចូលរួមនិងការពិគ្រោះយោបល់

ក្នុងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ចាំបាច់ត្រូវមានការសិក្សាស្វែងយល់ពីសហគមន៍មូលដ្ឋានដែលមានសកម្មភាព ដូចខាងក្រោម ៖

## ១-១ បង្កើតក្រុមការងារ

ក- ការរៀបចំក្រុមការងារ អាចមានចំនួន៣ទៅ៥នាក់ រួមមាន មន្ត្រីរដ្ឋបាលការពារនិងអភិរក្សធម្មជាតិក្រុមប្រឹក្សាឃុំ សង្កាត់ ដៃគូអភិវឌ្ឍន៍ ឬស្ថាប័ន ពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។ ស្ត្រីត្រូវបានលើកទឹកចិត្តឱ្យចូលរួម ក្នុងសមាសភាពក្រុមការងារនេះ។

ខ- ក្រុមការងារ មានតួនាទីក្នុងការសិក្សាស្រាវជ្រាវ និងជាអ្នកសម្របសម្រួលក្នុងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ។

## ១-២ វិធីសាស្ត្រនៃការសិក្សា

ក- ជ្រើសរើសវិធីសាស្ត្រសិក្សាវាយតម្លៃដោយមានការចូលរួម និងសមស្របសម្រាប់ការអនុវត្តទៅតាមស្ថានភាពជាក់ស្តែងក្នុងតំបន់នីមួយៗ។

ខ- ជ្រើសរើសអ្នកសំខាន់ៗក្នុងសហគមន៍មូលដ្ឋាន ដើម្បីចូលរួមផ្តល់ព័ត៌មាននៅក្នុងការសិក្សាស្រាវជ្រាវ។

គ- ប្រមូល និងប្រើប្រាស់ព័ត៌មានដែលមានស្រាប់ជាមូលដ្ឋានសម្រាប់ការវិភាគ។

ឃ-កំណត់តម្រូវការ ប្រភេទព័ត៌មាន ដែលឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ។

ង- លទ្ធផលនៃការសិក្សាត្រូវបង្ហាញនិងពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន

## ១-៣ តំបន់អាទិភាពសម្រាប់ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

ក- តំបន់ដែលមានសក្តានុពលផ្នែកទេសចរណ៍ធម្មជាតិ ។

ខ- តំបន់ដែលងាយទទួលរងការបាត់បង់ធនធានធម្មជាតិ និងមានប្រជាពលរដ្ឋភាគច្រើនពឹងអាស្រ័យលើការប្រាស់ធនធានធម្មជាតិសម្រាប់ការចិញ្ចឹមជីវិត

គ- តំបន់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលបាននឹងកំពុងប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណីសម្រាប់ការចិញ្ចឹមជីវិត។

ឃ-តំបន់ដែលមានការចាប់អារម្មណ៍ពី សហគមន៍មូលដ្ឋាន និងអាជ្ញាធរដែនដីគាំទ្រចូលរួមក្នុងការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ។

## ១-៤ ការពិគ្រោះយោបល់និងការសម្រេចចិត្តរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

ក- លទ្ធផលសំខាន់ៗនៃការសិក្សាដែលត្រូវបង្ហាញ និងពិគ្រោះយោបល់ រួមមានៈ ទំនាក់ទំនងមុខរបរចិញ្ចឹម ជីវិតទៅនឹងធនធានព្រៃឈើ ប្រវត្តិនៃការប្រែប្រួលនៃធនធានធម្មជាតិក្នុងតំបន់និងបញ្ហាសំខាន់ៗដែលកំពុងកើតមានក្នុងសហគមន៍។

ខ- ក្រុមសម្របសម្រួល ត្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ប្រកាសគោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ព្រមទាំងសារៈប្រយោជន៍នៃសហគមន៍តំបន់ការពារធម្មជាតិ។

គ- ការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ត្រូវស្វែងយល់ពីទឹកចិត្តចូលរួមរបស់ប្រជាពលរដ្ឋ មុននឹងឈានទៅដល់ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ។

ឃ- ទម្រង់គំរូរបាយការណ៍សិក្សាវាយតម្លៃសក្តានុពលនៃការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ មាននៅក្នុងឧបសម្ព័ន្ធទី៨ នៃគោលការណ៍ណែនាំ។

# ជំហានទី ២
# ការស្នើសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

## ២-១ ការស្នើសុំក្រុមការងារបច្ចេកទេសជួយសម្របសម្រួល

ក- ពេលដែលសហគមន៍មូលដ្ឋានឯកភាពដើម្បីរៀបចំជាសហគមន៍តំបន់ការពារធម្មជាតិ មេភូមិ ឬតំណាងសហគមន៍ អាចធ្វើសំណើសុំជំនួយបច្ចេកទេស និងសម្ភារៈ ពីនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ តាមរយៈ អាជ្ញាធរដែនដី និងរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ក្នុងមូលដ្ឋាន។ សហគមន៍មូលដ្ឋានអាចបញ្ចូលសកម្មភាព ជាអាទិភាពនៃការរៀបចំសហគមន៍តំបន់ការពារ

ធម្មជាតិ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដើម្បីសុំជំនួយថវិកា សំភារៈ និងបច្ចេកទេស។

ខ- ក្រុមការងារបច្ចេកទេស មានតួនាទីជួយសម្របសម្រួល និងផ្តល់យោបល់ក្នុងដំណើរការរៀបចំសហគមន៍ តំបន់ការពារធម្មជាតិ។

## ២-២ ការសុំចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ

ក- ក្នុងករណីមិនទាន់មានគណៈកម្មការ តំណាងសមាជិកសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើបញ្ជីចុះឈ្មោះគ្រួសារដែលស្ម័គ្រចិត្តចូលរួម ដោយមានស្នាមមេដៃជាភស្តុតាង។

ខ- គ្រួសារនីមួយៗដែលស្ម័គ្រចិត្តចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ ត្រូវបំពេញពាក្យជាលាយល័ក្ខអក្សរ ដើម្បីសុំចូលជាសមាជិកជូនទៅគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ។

គ- ទម្រង់គំរូពាក្យសុំចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ មានក្នុងឧបសម្ព័ន្ធ ទី១ នៃគោលការណ៍ណែនាំ។

## ២-៣ ការសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

ក- តំណាងសមាជិកសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើលិខិតស្នើសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិទៅក្រសួងបរិស្ថាន តាមរយៈមេឃុំ ចៅសង្កាត់ នាយកតំបន់ការពារធម្មជាតិ អភិបាលស្រុក អភិបាលក្រុង ប្រធានមន្ទីរបរិស្ថាន អភិបាលខេត្ត និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ។

ខ- ទម្រង់គំរូលិខិតស្នើសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិ មានក្នុងឧបសម្ព័ន្ធទី២ នៃគោលការណ៍ណែនាំ។

# ជំហានទី ៣
# ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

ការជ្រើសរើសគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើឡើងតាមការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ រចនាសម្ព័ន្ធគ្រប់គ្រង អាចមានពីរឬបីលំដាប់ថ្នាក់ អាស្រ័យលើស្ថានភាពជាក់ស្តែងនៃចំនួនភូមិដែលបានចូលរួម។

## ៣-១ លក្ខខណ្ឌនៃការជ្រើសរើសបេក្ខជនឈរឈ្មោះបោះឆ្នោត

ក- រស់នៅជាអចិន្ត្រៃយ៍ក្នុងសហគមន៍មូលដ្ឋាន

ខ- មានប្រវត្តិច្បាស់លាស់ និងមានសីលធម៌រស់នៅល្អ

គ- មានសុឆន្ទៈបម្រើការងារក្នុងសហគមន៍

ឃ-មានភាពស្មោះត្រង់ និងមានការទទួលខុសត្រូវ

ង- ស្គាល់ទីតាំងភូមិសាស្ត្រច្បាស់លាស់

ច- ចេះអាន និងចេះសរសេរអក្សរខ្មែរ

ឆ- មានទំនាក់ទំនងល្អ

ជ- មានសុខភាពមាំមួន

ឈ- មិនមែនជាអាជ្ញាធរដែនដី ឬមន្ត្រីរាជការ

ញ- មានអាយុចាប់ពី២៥ឆ្នាំឡើងទៅ

ដ- ការជ្រើសរើសបេក្ខជនឈរឈ្មោះជាគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវតែមានការឯកភាព និងស្ម័គ្រចិត្តពីសាមីខ្លួនផ្ទាល់។

## ៣-២ នីតិវិធីនៃការបោះឆ្នោត

ក- ជ្រើសរើសក្រុមការងារបណ្តោះអាសន្ន ដើម្បីសម្របសម្រួលរៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍។ ក្រុមការងារនេះអាចជាគណៈកម្មការវត្ត គ្រូ បង្រៀន ព្រះសង្ឃ ចាស់ទុំក្នុងភូមិ ឬសមាជិកសហគមន៍ដែលមិនមែនជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

ខ- ក្រុមការងារសម្របសម្រួលត្រូវប្រជុំពិភាក្សាជ្រើសរើសបេក្ខជនឈរឈ្មោះ ផ្អែកតាមលក្ខណៈវិនិច្ឆ័យ(ក្នុងចំណុច៣-១)។

គ- ក្រុមការងារសម្របសម្រួល ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះគ្រួសារសមាជិកសហគមន៍តំបន់ការពារធម្មជាតិ ដែលត្រូវចូលរួមបោះឆ្នោត ព្រមទាំងរៀបចំសម្ភារៈបម្រើការបោះឆ្នោត ដូចជា៖ សន្លឹកឆ្នោត ប៊ិច ហិបឆ្នោត ទៅតាមលទ្ធភាពជាក់ស្តែងក្នុងសហគមន៍។

ឃ-ក្រុមការងាររៀបចំបោះឆ្នោត ត្រូវបង្ហាញបេក្ខជនឈរឈ្មោះ របៀបនៃការបោះឆ្នោតនិងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគណៈកម្មការសហគមន៍តំបន់ការពារ ធម្មជាតិ។

ង- ក្រុមការងាររៀបចំបោះឆ្នោត សហការជាមួយមេភូមិ ដើម្បីអញ្ជើញសមាជិកសហគមន៍ តំបន់ការពារធម្មជាតិ ក្នុងរយៈពេល៣ទៅ៥ថ្ងៃ មុនថ្ងៃបោះឆ្នោត។

ច- តំណាងគ្រួសារដែលចូលរួមបោះឆ្នោតត្រូវមានអាយុ១៨ឆ្នាំឡើងទៅ។

ឆ- អ្នកចូលរួមបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតតែមួយដង និងមួយសន្លឹកគត់។

ជ- ក្រុមការងាររៀបចំបោះឆ្នោត ត្រូវអញ្ជើញក្រុមប្រឹក្សាឃុំ សង្កាត់ នាយកតំបន់ការពារធម្មជាតិ មន្ទីរបរិស្ថាន ចូលរួមជាអធិបតី និងសង្កេតការណ៍ ក្នុងពេលបោះឆ្នោត។

ឈ-បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាង គឺជាប្រធាន និងបេក្ខជនដែលមានសំឡេងឆ្នោតបន្ទាប់ គឺជាអនុប្រធានគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ (ករណីសម្លេងគាំទ្ររវាងបុរស និងស្ត្រីស្មើគ្នា ស្ត្រីគឺជាអាទិភាពធ្វើជាប្រធាន)។

ញ-ការរាប់សន្លឹកឆ្នោតត្រូវធ្វើឡើងបន្ទាប់ពីការបោះឆ្នោតចប់(ក្នុងថ្ងៃតែមួយ) ក្រុមការងាររៀបចំការបោះ ឆ្នោតត្រូវបង្ហាញលទ្ធផលនៅចំពោះមុខអ្នកចូលរួម។

ដ- ក្រុមការងាររៀបចំការបោះឆ្នោត ត្រូវធ្វើកំណត់ហេតុស្តីពីដំណើរការ និងលទ្ធផលនៃការបោះឆ្នោត ដើម្បីផ្ញើជូនក្រុមប្រឹក្សាឃុំ សង្កាត់ នាយកតំបន់ការពារធម្មជាតិ និងតម្កល់ទុកក្នុងសហគមន៍។

## ៣-៣ រចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

ក- ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ មានពីរឬបីលំដាប់ថ្នាក់អាស្រ័យលើចំនួនភូមិដែលចូលរួម ដូចជា៖ ថ្នាក់ក្រុម ថ្នាក់អនុគណៈកម្មការ និងថ្នាក់គណៈកម្មការអមដោយទីប្រឹក្សា និងអ្នកគាំទ្រ (ដូចមាន ក្នុងឧបសម្ព័ន្ធទី៣)។

ខ- ការរៀបចំក្រុម ត្រូវមានសមាជិកពី១៥ទៅ២០គ្រួសារ អាស្រ័យលើស្ថានភាពជាក់ស្តែង។ ក្នុងមួយក្រុមត្រូវមានប្រធាន១រូប និងអនុប្រធាន២រូប ដោយមានការឯកភាពជ្រើសតាំងពីសមាជិកក្នុងក្រុម។

គ- ការរៀបចំអនុគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ អាចមានចំនួន៣រូប ដែលជាអ្នកទទួលខុសត្រូវក្នុងភូមិនីមួយៗ។

ឃ-ការរៀបចំគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ជាចំនួនសេស អាចមានចំនួន ៧នាក់ ៩នាក់ ឬ១១រូប អាស្រ័យលើតម្រូវការជាក់ស្តែងនៅក្នុងសហគមន៍នីមួយៗ។ សមាសភាពគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានស្ត្រីចូលរួម។

## ៣-៤ តួនាទីនិងការអនុវត្ត

ក- បេក្ខជនដែលបានជាប់ឆ្នោតជាគណៈកម្មការ ត្រូវពិភាក្សាបែងចែកតួនាទីអនុវត្តមុនពេលរៀបចំលក្ខន្តិកៈ។

ខ- ក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ក្រោយពេលជាប់ឆ្នោត គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានដីកាទទួលស្គាល់ពីមេឃុំ ចៅសង្កាត់ ដើម្បីឱ្យគណៈកម្មការនេះក្លាយជានីតិបុគ្គល ដឹកនាំការងារក្នុងសហគមន៍ តំបន់ការពារធម្មជាតិនិងមានសិទ្ធិចុះកិច្ចព្រមព្រៀងជាមួយ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ។

## ជំហានទី ៤

## ការកំណត់ទីតាំងព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ

របៀបនៃការកំណត់ទីតាំងព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ អាចមានលក្ខណៈខុសប្លែកគ្នាទៅតាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗ និងគោលបំណង នៃការគ្រប់គ្រងរបស់សហគមន៍ ដូចជា៖ ការគ្រប់គ្រងផ្តោតលើ ធនធានព្រៃឈើ ធនធានជលផល ទីជម្រាលកូទេសចរណ៍ ការប្រើប្រាស់ទឹក និងការប្រើប្រាស់ដី ដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ។ ជារួមរបៀបនៃការកំណត់ទីតាំងព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ ត្រូវអនុវត្តសកម្មភាពដូចខាងក្រោម ៖

### ៤-១ កិច្ចពិភាក្សាលើការកំណត់ទីតាំងព្រំប្រទល់

ក- តំណាងគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងក្រុមការងារសម្របសម្រួល ត្រូវធ្វើការប្រជុំពិភាក្សា ដោយមានការចូលរួមពីប្រធានក្រុម និងសមាជិកសំខាន់ៗក្នុងសហគមន៍ ដើម្បីព្រាងចំណុចទីតាំងព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ ដោយផ្អែកលើព័ត៌មាន ដែលមានស្រាប់ និងផែនទីដោយមានការចូលរួម ឬផែនទីមាត្រដ្ឋាន។

ខ- ការកំណត់ទីតាំងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើឡើងស្របទៅមាត្រា ២៧នៃច្បាប់ ស្តីពី តំបន់ការពារធម្មជាតិ និងគោលបំណងជាក់លាក់នៃការចូលរួមគ្រប់គ្រងរបស់សហគមន៍។

គ- កិច្ចពិភាក្សាត្រូវគិតពីទំហំផ្ទៃដីសមស្រប និងលទ្ធភាពគ្រប់គ្រងរបស់សហគមន៍ទៅនឹងស្ថានភាពជាក់ស្តែង។

ឃ-ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ គួរយកចំណុចទីតាំងជាលក្ខណៈធម្មជាតិដូចជា ៖ អូរ ស្ទឹង ឬផ្លូវ (ប្រសិនបើមាន)។

ង- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយនាយកតំបន់ការពារធម្មជាតិ ពីចំណុចព្រាងលើផែនទីមាត្រដ្ឋាន មុននឹងចុះពិនិត្យដល់ទីតាំងជាក់ស្តែង។ នាយកតំបន់ការពារធម្មជាតិ ត្រូវផ្តល់យោបល់ដោយផ្អែកលើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងលិខិតបទដ្ឋានច្បាប់។

## ៤-២ ការចុះកំណត់ទីតាំងជាក់ស្តែងជាមួយនាយកតំបន់ការពារធម្មជាតិ

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ អាជ្ញាធរមូលដ្ឋាន នាយកតំបន់ការពារធម្មជាតិ ត្រូវចុះសិក្សាពិនិត្យលើចំណុចទីតាំងជាក់ស្តែងនៃព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ។

ខ- តាមចំណុចទីតាំងព្រំប្រទល់សំខាន់ៗ ត្រូវលាបថ្នាំ ដាក់សញ្ញាសំគាល់ ឬបោះកំសួល(ចំពោះដែនទឹក) ជាបណ្តោះអាសន្ន សម្រាប់សញ្ញាផ្តល់ដំណឹងដល់សមាជិក ឬអ្នកពាក់ព័ន្ធដែលមានបំណងចង់ធ្វើការតវ៉ាលើការកំណត់ទីតាំងព្រំប្រទល់នោះ។

គ- អ្នកសម្របសម្រួល ត្រូវធ្វើកំណត់ហេតុ និងចុះបញ្ជីវត្តមានអ្នកចូលរួម ក្នុងពេលចុះកំណត់ទីតាំងព្រំប្រទល់របស់សហគមន៍។

## ៤-៣ ការសម្របសម្រួលដោះស្រាយបញ្ហាដែលអាចកើតមាន

ក- ក្នុងករណីគ្មានបញ្ហាកើតឡើង ត្រូវឈានចូលចំណុចទី(៤-៤)។

ខ- ក្នុងករណីមានបញ្ហា គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើការសម្របសម្រួលដោះស្រាយ។

គ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវអញ្ជើញមន្ទីរបរិស្ថាន នាយកតំបន់ការពារធម្មជាតិ និងអាជ្ញាធរមូលដ្ឋាន ដើម្បីសម្របសម្រួលដោះស្រាយដោយឈរលើមូលដ្ឋានច្បាប់និងផលប្រយោជន៍សហគមន៍។

## ៤-៤ ការចុះកំណត់ទីតាំងព្រំប្រទល់ជាក់លាក់

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវស្នើសុំជំនួយបច្ចេកទេស និងសម្ភារៈ ពីនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ ក្នុងការកំណត់ទីតាំងព្រំប្រទល់ ដោយប្រើឧបករណ៍ជីភីអេស(GPS) និងកំណត់ តាមប្រព័ន្ធ DATUM : WGS 84 ។

ខ- ការចុះកំណត់ទីតាំងព្រំប្រទល់ជាក់លាក់ ត្រូវមានការចូលរួមពីក្រុមប្រឹក្សាឃុំសង្កាត់ នាយកតំបន់ការពារធម្មជាតិ ឬអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

គ- ការកំណត់យកចំណុចទីតាំងព្រំប្រទល់ ត្រូវមានការឯកភាពនិងកត់ត្រាយកចំណុចនិយាមកា។

ឃ-អ្នកសម្របសម្រួលត្រូវធ្វើកំណត់ហេតុ និងចុះបញ្ជីវត្តមានអ្នកចូលរួម ក្នុងពេលចុះកំណត់ទីតាំងព្រំប្រទល់។

| ចំណុច | ឈ្មោះអ្នកភូមិហៅ | អាប់ស៊ីស X | អ័រដោនេ Y |
|---|---|---|---|
| A | ឱ. ចំបក់កោង | | |
| B | | | |
| C | | | |

## ៤-៥ ការរៀបចំផែនទីមាត្រដ្ឋាន

ក- នាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ ជួយសម្របសម្រួលក្នុងការរៀបចំធ្វើផែនទីមាត្រដ្ឋាន ។

ខ- ផែនទីសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមាននិយាមកា និងមាត្រដ្ឋានច្បាស់លាស់ ដោយប្រើតាមប្រព័ន្ធ DATUM : WGS 84 ព្រមទាំងមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។

## ៤-៦ ការដាក់បង្គោលសញ្ញាសំគាល់ព្រំប្រទល់

ក- ការដាក់បង្គោលសម្គាល់ព្រំប្រទល់ព្រៃសហគមន៍ ត្រូវធ្វើតាមចំណុចនិយាមកាដែល មានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ឬទីតាំងសំខាន់ៗ ដែលសហគមន៍យល់ឃើញថាចាំបាច់សម្រាប់ការផ្សព្វផ្សាយនិងហាមឃាត់។

ខ- ការដាក់បង្គោលសម្គាល់ទីតាំងព្រំប្រទល់ព្រៃសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើឡើងដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ។

គ- នៅលើបង្គោលព្រំ ត្រូវមានដាក់លេខរៀងបង្គោល ឈ្មោះសហគមន៍ និងលេខនិយាមកា(UTM)។

ឃ-នៅតាមចន្លោះបង្គោលព្រំប្រទល់ព្រៃសហគមន៍ ត្រូវមានស្លាកសញ្ញាសំគាល់ស្លាក សញ្ញាហាមឃាត់នានា ស្របតាមលក្ខខណ្ឌចាំបាច់របស់សហគមន៍នីមួយៗ។

# ជំហានទី ៥
# ការរៀបចំលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ

ការរៀបចំលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ អាចមានលក្ខណៈខុសប្លែកគ្នាទៅតាមស្ថានភាពជាក់ស្តែងក្នុងតំបន់នីមួយៗ និងគោលបំណងនៃការគ្រប់គ្រងរបស់សហគមន៍ ដូចជា៖ ការគ្រប់គ្រងផ្តោតលើអេកូទេសចរណ៍ ធនធានជលផល ធនធានព្រៃឈើ ទីជម្រាល ការប្រើប្រាស់ទឹក និងការប្រើប្រាស់ដីធ្លីដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ។ ការរៀបចំលក្ខន្តិកៈត្រូវផ្តោតលើកត្តាសំខាន់បីគឺ៖

- ត្រូវមានការចូលរួមពីសមាជិកសហគមន៍

- ខ្លឹមសារនៃលក្ខន្តិកៈស្របនឹងបទដ្ឋានច្បាប់
- ខ្លឹមសារនៃលក្ខន្តិកៈត្រូវស្របទៅតាមគោលបំណងនៃការគ្រប់គ្រងនិងអាចអនុវត្តបាន។

ជារួមដំណើរការរៀបចំលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិត្រូវអនុវត្តតាមចំណុចដូចខាងក្រោម ៖

## ៥-១ ការខារត្រៀមរៀបចំលក្ខន្តិកៈ

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ អាចស្នើសុំជំនួយបច្ចេកទេសពីនាយក ដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ មន្ទីរបរិស្ថាន នាយកតំបន់ការពារធម្មជាតិ ឬដៃគូអភិវឌ្ឍន៍។

ខ- អ្នកសម្របសម្រួល ត្រូវត្រៀមរៀបចំបញ្ជីសំណួរសម្រាប់បំផុសគំនិត និងត្រៀមលិខិតបទដ្ឋានច្បាប់នានាដែលពាក់ព័ន្ធ ដើម្បីជួយបំភ្លឺដល់សហគមន៍។

គ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងអ្នកសម្របសម្រួល ត្រូវធ្វើការពិភាក្សាកំណត់ជ្រើសរើសអ្នកចូលរួម ពេលវេលានិងទីកន្លែងឱ្យបានសមស្រប។

ឃ-គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិត្រូវធ្វើលិខិតអញ្ជើញអ្នកដែលត្រូវចូលរួម។

## ៥-២ ការរៀបចំសេចក្ដីព្រាងលក្ខន្តិកៈ

ក- អ្នកចូលរួមរៀបចំសេចក្តីព្រាងលក្ខន្តិកៈលើកទីមួយ មានដូចជា៖ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ មេភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកសំខាន់ៗក្នុង សហគមន៍ដែលមានចំនួនសរុបក្នុងចន្លោះពី២០ទៅ៣០នាក់ ក្នុងនោះស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការចូលរួម។

ខ- អ្នកចូលរួម ត្រូវបង្កើតវិន័យរួមមួយ មុនពេលចាប់ផ្តើមរៀបចំសេចក្តីព្រាងលក្ខន្តិកៈ ដើម្បីជៀសវាងទំនាស់ឬខ្វែងគំនិតគ្នាក្នុងការបញ្ចេញមតិយោបល់ និងងាយស្រួលក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

គ- ក្នុងពេលចាប់ផ្តើម អ្នកសម្របសម្រួលត្រូវពន្យល់ណែនាំដល់អ្នកចូលរួមអំពីអ្វីទៅជាលក្ខន្តិកៈ? មានសារៈសំខាន់អ្វីខ្លះ? និងមានការទទួលស្គាល់ពីស្ថាប័នណាខ្លះ?។

ឃ-អ្នកចូលរួម ត្រូវពិភាក្សាលើមាតិកានៃលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ

ង- ក្នុងដំណើរការពិភាក្សា អ្នកសម្របសម្រួល ត្រូវលើកជាសំណួរឱ្យបានច្បាស់លាស់ និងស្នើឱ្យអ្នកចូលរួមបញ្ចេញគំនិតយោបល់ឱ្យបានផុលផុស។ ករណីខ្លះ កិច្ចពិភាក្សាអាចបែងចែកជាក្រុម។ អ្នកសម្របសម្រួល ត្រូវសំយោគគំនិតតាមមតិភាគច្រើន និងបញ្ជាក់ឡើងវិញពីខ្លឹមសារដែលបានសំយោគ។

ច- ខ្លឹមសារនៃប្រការនីមួយៗ ត្រូវមានលក្ខណៈស្របនឹងបទដ្ឋានច្បាប់ និង សហគមន៍ដែលអាចអនុវត្តបាន។

ឆ- ទម្រង់គំរូនៃលក្ខន្តិកៈមានក្នុងឧបសម្ព័ន្ធទី៣ នៃគោលការណ៍ណែនាំ។

## ៥-៣ ការពិគ្រោះយោបល់សេចក្តីព្រាងលក្ខន្តិកៈជាមួយសមាជិក

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវយកសេចក្តីព្រាងលក្ខន្តិកៈ ទៅធ្វើការប្រជុំពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍។ ក្នុងករណី សហគមន៍មានការចូលរួមចាប់ពី២ភូមិឡើងទៅសកម្មភាពនេះ ត្រូវធ្វើឡើងទៅតាមភូមិនីមួយៗ។

ខ- សមាជិកសហគមន៍តំបន់ការពារធម្មជាតិ មានសិទ្ធិចូលរួមផ្តល់យោបល់លើ សេចក្តីព្រាងលក្ខន្តិកៈដោយបញ្ជាក់ពីហេតុផលច្បាស់លាស់ ក្នុងការកែសម្រួលលើប្រការណាមួយ។

គ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ជាអ្នកធ្វើបទបង្ហាញ និងឆ្លើយបំភ្លឺដល់សមាជិក។ អ្នកសម្របសម្រួលអាចជួយបំភ្លឺបន្ថែម លើចំណុចណាមួយដែលមិនទាន់ច្បាស់។

ឃ-សមាជិកសហគមន៍តំបន់ការពារធម្មជាតិ ដែលមិនបានចូលរួមក្នុងការប្រជុំ ពិគ្រោះយោបល់ត្រូវចាត់ទុកថាបានឯកភាពលើសេចក្តីព្រាងលក្ខន្តិកៈ។

ង- ការប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងលក្ខន្តិកៈសហគមន៍តំបន់ការពារ ធម្មជាតិ

អាចដំណើរការទៅបានលុះត្រាតែមានសមាជិកចូលរួមចំនួនហុកសិបភាគរយ(៦០%) នៃចំនួនសរុបសមាជិកសហគមន៍។

## ៥-៤ ការពិគ្រោះយោបល់សេចក្តីព្រាងលក្ខន្តិកៈជាមួយអ្នកពាក់ព័ន្ធ

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវយកសេចក្តីព្រាងលក្ខន្តិកៈ ទៅធ្វើការប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីសុំយោបល់កែលម្អ លើសេចក្តីព្រាងលក្ខន្តិកៈនោះ។

ខ- អ្នកពាក់ព័ន្ធដែលត្រូវអញ្ជើញចូលរួមមាន៖ មន្ទីរបរិស្ថាន នាយកតំបន់ការពារ ធម្មជាតិ មេភូមិជិតខាង ក្រុមប្រឹក្សាឃុំ សង្កាត់សាមុី ក្រុមប្រឹក្សាឃុំ សង្កាត់ជិត ខាង អភិបាលស្រុក អភិបាលក្រុង និងដៃគូអភិវឌ្ឍន៍។

គ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើលិខិតអញ្ជើញទៅអ្នក ពាក់ព័ន្ធ ដោយមានភ្ជាប់ជាមួយនូវសេចក្តីព្រាងលក្ខន្តិកៈ។

ឃ-គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ជាអ្នកធ្វើបទបង្ហាញពីគោលបំណងនៃកិច្ចប្រជុំ និងខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងលក្ខន្តិកៈ ព្រមទាំងជាអ្នកឆ្លើយបំភ្លឺ។ អ្នកសម្របសម្រួលអាចជួយបំភ្លឺបន្ថែមលើចំណុចណាមួយដែលមិនទាន់ច្បាស់ ។

ង- កិច្ចពិភាក្សាអាចធ្វើឡើងមួយប្រការម្តង ឬមួយជំពូកម្តង អាស្រ័យលើការឯកភាពពីអ្នកចូលរួម។

ច- អ្នកសម្របសម្រួល ត្រូវជួយធ្វើកំណត់ហេតុ និងចុះបញ្ជីវត្តមាន ដោយមានហត្ថលេខា ពីប្រធានអង្គប្រជុំដើម្បីជាឯកសារភ្ជាប់នៅពេលសុំការទទួលស្គាល់លក្ខន្តិកៈ។

ឆ- អ្នកសម្របសម្រួល ត្រូវជួយគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិក្នុងការកែសម្រួលសេចក្តីព្រាងលក្ខន្តិកៈចុងក្រោយ ។

ជ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវដាក់ជូនសេចក្តីព្រាងលក្ខន្តិកៈទៅនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីជួយពិនិត្យនិងកែសម្រួល មុននឹងចុះហត្ថលេខាលើលក្ខន្តិកៈ។ រយៈពេលនៃការពិនិត្យមិនឱ្យលើសពី១៥ថ្ងៃ(ថ្ងៃធ្វើការ) គិតចាប់ពីថ្ងៃនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិទទួលបានឯកសារ។

## ៥-៥ ការសុំទទួលស្គាល់លក្ខន្តិកៈ

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវរៀបចំលិខិតសុំការទទួលស្គាល់លក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ។

ខ- លក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានការចុះហត្ថលេខាទទួលស្គាល់ពីមេឃុំ ចៅសង្កាត់ នាយកតំបន់ការពារធម្មជាតិ អភិបាលស្រុក អភិបាលក្រុង មន្ទីរបរិស្ថាន និងអភិបាលខេត្ត។

គ- ច្បាប់ដើមនៃលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ត្រូវតម្កល់ទុកក្នុងសហគមន៍ ស្ថាប័នដែលបានចុះហត្ថលេខា និងនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ។

# ជំហានទី ៦
# ការរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

ការរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើឡើងស្របទៅតាមមាត្រា២៨ នៃច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ និងមានដំណើរការដូចខាងក្រោម ៖

## ៦.១ ការកំណត់តំបន់គ្រប់គ្រង

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវរៀបចំកិច្ចពិភាក្សាដើម្បីធ្វើការបែងចែកតំបន់គ្រប់គ្រងជាមួយនឹងសមាជិកដែលមានចំណេះដឹងពាក់ព័ន្ធទៅនឹងស្ថានភាពភូមិ សាស្ត្រតំបន់ព្រៃសហគមន៍។

ខ- ការបែងចែកតំបន់គ្រប់គ្រងនីមួយៗផ្អែកតាមស្ថានភាពនិងប្រភេទព្រៃឈើ និងភូមិសាស្ត្រឆ្លើយតបនឹងគោលបំណងនៃការគ្រប់គ្រង និងប្រើប្រាស់ក្នុងសហគមន៍។

គ-ការបែងចែកតំបន់គ្រប់គ្រងធ្វើឡើងដោយផ្អែកលើផែនទីដែលទទួលស្គាល់ពីក្រសួង បរិស្ថាន។

ឃ-ការបែងចែកតំបន់គ្រប់គ្រងនីមួយៗ ត្រូវកំណត់ទំហំផ្ទៃដីច្បាស់លាស់ដើម្បីជាមូលដ្ឋានក្នុងការធ្វើសារពើភ័ណ្ឌព្រៃសហគមន៍។

## ៦-២.ការសិក្សាប៉ាន់ប្រមាណពីធនធានធម្មជាតិ (សារពើភ័ណ្ឌព្រៃឈើសហគមន៍)

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ អាចស្នើសុំជំនួយបច្ចេកទេសពីនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ មន្ទីរបរិស្ថាន នាយកតំបន់ការពារធម្មជាតិ និងដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រដំណើរការរៀបចំផែនការគ្រប់គ្រង។

ខ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងអ្នកសម្របសម្រួល ត្រូវពិភាក្សារៀបចំការសិក្សាប៉ាន់ ប្រមាណធនធានធម្មជាតិ ( សារពើភ័ណ្ឌព្រៃសហគមន៍ )។

គ- អ្នកសម្របសម្រួល ត្រូវរៀបចំវិធីសាស្ត្រសារពើភ័ណ្ឌព្រៃសហគមន៍ ស្របតាមគោលបំណងនៃការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ។

ឃ-គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវប្រជុំពិភាក្សាជាមួយអ្នកសម្របសម្រួល ដោយផ្អែកលើព័ត៌មានដែលមានស្រាប់ស្របទៅតាមស្ថានភាពជាក់ស្តែងដើម្បីធ្វើការបែងចែកតំបន់ ឬអនុតំបន់សម្រាប់ធ្វើសារពើភ័ណ្ឌព្រៃសហគមន៍។

ង- អ្នកសម្របសម្រួល ត្រូវធ្វើការបណ្តុះបណ្តាលដល់អ្នកចូលរួមអំពីវិធីសាស្ត្រនៃការធ្វើសារពើភ័ណ្ឌព្រៃសហគមន៍។ សកម្មភាពនេះអាចធ្វើការណែនាំ ក្នុងពេលអនុវត្តជាក់ស្តែង ឬបណ្តុះបណ្តាល១សប្តាហ៍មុនពេលចាប់ផ្តើមធ្វើសារពើភ័ណ្ឌព្រៃឈើ។

ច- ការអនុវត្តត្រូវធ្វើឡើងទៅតាមវិធីសាស្ត្របច្ចេកទេស ក្នុងតំបន់ ឬអនុតំបន់ដែលបានកំណត់និងធ្វើការវិភាគយកទិន្នន័យជាមូលដ្ឋានសម្រាប់កិច្ចពិភាក្សារៀបចំផែនការគ្រប់គ្រង។

## ៦-៣ ការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ក្នុងសហគមន៍

ក- ការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ធនធានធម្មជាតិរបស់សហគមន៍ ដើម្បីធ្វើការប្រៀបធៀបរវាងការប្រើប្រាស់ និងធនធានធម្មជាតិដែលមានក្នុងព្រៃសហគមន៍ សម្រាប់ជាមូលដ្ឋាននៅក្នុងកិច្ចពិភាក្សារៀបចំផែនការគ្រប់គ្រងសហគមន៍។

ខ- ការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ធនធានធម្មជាតិរបស់សហគមន៍ ត្រូវធ្វើឡើងដោយអ្នកសម្របសម្រួល និងគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ក្រុមប្រឹក្សា ឃុំ សង្កាត់ ឬដៃគូអភិវឌ្ឍន៍។

គ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងអ្នកសម្របសម្រួល ត្រូវពិភាក្សារៀបចំបញ្ជីសំណួរ ដោយកំណត់ពីប្រភេទធនធានដែលសហគមន៍បាន នឹងកំពុងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ស្របទៅតាមគោលបំណងនៃការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។

ឃ-ការសិក្សាត្រូវធ្វើតាមរយៈ កិច្ចសម្ភាសន៍ និងបញ្ជីសំណួរ ដែលបានគ្រោងទុកលើគ្រួសារចំនួន១០%ទៅ២០% នៃចំនួនគ្រួសារសរុបរបស់សមាជិកសហគមន៍ ការសម្ភាសន៍ត្រូវជ្រើសរើសគ្រួសារដែលមានស្ថានភាពជីវភាពខុសៗគ្នា។

ង- ការវិភាគលទ្ធផល ត្រូវគណនាបរិមាណប្រើប្រាស់ជាមធ្យមភាគនៅក្នុង១គ្រួសារ និងក្នុងសហគមន៍ក្នុងមួយឆ្នាំ ។

## ៦-៤ កិច្ចពិភាក្សារៀបចំសេចក្តីព្រាងផែនការគ្រប់គ្រង

ក- កិច្ចពិភាក្សារៀបចំសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវឈរលើទិន្នន័យដែលបានមកពីការសិក្សាប៉ាន់ប្រមាណធនធានធម្មជាតិក្នុងតំបន់ព្រៃសហគមន៍  និងតម្រូវការប្រើប្រាស់នៅក្នុងសហគមន៍ រួមទាំងគោលបំណងជាក់លាក់ស្របទៅតាមស្ថាន ភាពជាក់ស្តែងក្នុងតំបន់នីមួយៗ។

ខ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវជ្រើសរើសសមាជិកដែលមានចំណេះដឹងដើម្បីចូលរួមក្នុងការរៀបចំសេចក្តីព្រាងផែនការគ្រប់គ្រងសម្រាប់រយៈពេល៥ឆ្នាំ។

គ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងអ្នកសម្របសម្រួល ត្រូវបង្ហាញពីគោលបំណងនៃការរៀបចំផែនការគ្រប់គ្រង និងលទ្ធផលនៃការសិក្សាប៉ាន់ប្រមាណធនធានធម្មជាតិក្នុងព្រៃសហគមន៍ និងតម្រូវការប្រើប្រាស់របស់សហគមន៍ ដល់អ្នកចូលរួមសម្រាប់ជាមូលដ្ឋានពិចារណាក្នុងកិច្ចពិភាក្សារៀបចំផែនការគ្រប់គ្រង។

ឃ-កិច្ចពិភាក្សារៀបចំសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវផ្តោតលើចំណុចមួយចំនួនដូចខាងក្រោម ៖

- ការបែងចែកតំបន់ ឬអនុតំបន់សំរាប់គ្រប់គ្រងស្របតាមស្ថានភាពជាក់ស្តែង
- គោលការណ៍ដកហូតនិងប្រើប្រាស់ធនធានធម្មជាតិ នៅក្នុងអនុតំបន់នីមួយៗ
- គោលការណ៍បែងចែកផលប្រយោជន៍ដោយមានតម្លាភាព គណនីភាព និងសមធម៌
- គោលការណ៍គ្រប់គ្រង និងប្រើប្រាស់ថវិកា ត្រូវបែងចែកទៅលើការងារអភិរក្ស ប៉ុន្មានភាគរយ? ការងារអភិវឌ្ឍន៍ប៉ុន្មានភាគរយ? ការងារមនុស្សធម៌ប៉ុន្មានភាគរយ? និងសម្រាប់មូលនិធិក្នុងសហគមន៍ប៉ុន្មានភាគរយ? ស្របតាមស្ថានភាពតម្រូវការជាក់ស្តែងរបស់ សហគមន៍តំបន់ការពារធម្មជាតិនីមួយៗ
- ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសហគមន៍ក្នុងរយៈពេល៥ឆ្នាំ ត្រូវគិតគូរពីការដាំស្តារព្រៃឡើងវិញ ឱកាសការធ្វើអាជីវកម្មខ្នាតតូចដែលមានសក្តានុពលក្នុងសហគមន៍ និងយុទ្ធសាស្ត្រសម្រាប់ភាពបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ
- ផែនការសកម្មភាពប្រតិបត្តិប្រចាំឆ្នាំ សមស្របតាមលទ្ធភាពជាក់ស្តែងដែលសហគមន៍អាចអនុវត្តបាន
- យន្តការត្រួតពិនិត្យ និងវាយតម្លៃ។

ង- សេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវរៀបចំចងក្រងជាឯកសារ ដូចមានទម្រង់គំរូ ក្នុងផ្នែកឧបសម្ព័ន្ធទី៤។

## ៦-៥ ការពិគ្រោះយោបល់សេចក្តីព្រាងផែនការគ្រប់គ្រង ជាមួយសមាជិកសហគមន៍

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវជូនដំណឹងដល់សមាជិកសហគមន៍ ពីពេលវេលា និងទីកន្លែង សម្រាប់ការប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការគ្រប់គ្រង។

ខ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ជាអ្នកធ្វើបទបង្ហាញពីចំណុចសំខាន់ៗ នៃសេចក្តីព្រាងផែនការគ្រប់គ្រងដល់អ្នកចូលរួម។

គ- សមាជិកសហគមន៍តំបន់ការពារធម្មជាតិ ដែលមិនបានចូលរួមក្នុងការប្រជុំពិគ្រោះយោបល់ត្រូវចាត់ទុកថាបានឯកភាពតាម និងត្រូវចូលរួមអនុវត្តតាមផែនការគ្រប់គ្រង។

ឃ-ការប្រជុំពិគ្រោះយោបល់លើ សេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិអាចដំណើរការទៅបានលុះត្រាតែមានសមាជិកចូលរួមចំនួនយ៉ាងតិចហុកសិបភាគរយ(៦០%)។

## ៦-៦ ការពិគ្រោះយោបល់សេចក្តីព្រាងផែនការគ្រប់គ្រងជាមួយអ្នកពាក់ព័ន្ធ

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវរៀបចំប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការគ្រប់គ្រងជាមួយអ្នកពាក់ព័ន្ធ រួមមាន៖ មន្ទីរបរិស្ថាន អាជ្ញាធរស្រុក/ក្រុង នាយកតំបន់ការពារធម្មជាតិ ក្រុមប្រឹក្សាឃុំ សង្កាត់ នាយកដ្ឋានជំនាញពាក់ព័ន្ធ ឬដៃគូអភិវឌ្ឍន៍។

ខ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើលិខិតអញ្ជើញដល់អ្នកពាក់ព័ន្ធដោយមានភ្ជាប់ជាមួយនូវសេចក្តីព្រាងផែនការគ្រប់គ្រង។

គ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ជាអ្នកធ្វើបទបង្ហាញពីសេចក្តីព្រាងផែនការគ្រប់គ្រងដល់អ្នកចូលរួម។

ឃ-អ្នកសម្របសម្រួល ត្រូវធ្វើកំណត់ហេតុស្តីពីកិច្ចប្រជុំ ដោយមានហត្ថលេខាប្រធានអង្គប្រជុំដើម្បីជាឯកសារភ្ជាប់នៅពេលសុំការទទួលស្គាល់ផែនការគ្រប់គ្រងសហគមន៍តំបន់ការ ពារធម្មជាតិ។

## ៦-៧ ការសុំទទួលស្គាល់ផែនការគ្រប់គ្រង

ក- គណៈកម្មការត្រូវរៀបចំលិខិតស្នើសុំការទទួលស្គាល់ផែនការគ្រប់គ្រង ។

ខ- ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវមានហត្ថលេខាទទួលស្គាល់ពីមេឃុំ ចៅសង្កាត់ នាយកតំបន់ការពារធម្មជាតិ ប្រធានមន្ទីរបរិស្ថាន អភិបាលស្រុក/ក្រុង និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ការពារនិងអភិរក្សធម្មជាតិ។

គ- ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវតម្កល់ទុកក្នុងសហគមន៍ស្ថាប័ន ដែលបានចុះហត្ថលេខា និងនាយកដ្ឋានសហគមន៍តំបន់ការពារ ធម្មជាតិ

# ជំហានទី ៧
# ការរៀបចំកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

## ៧-១ ការរៀបចំសេចក្តីព្រាងនៃកិច្ចព្រមព្រៀង

ក- សហគមន៍តំបន់ការពារធម្មជាតិ អាចស្នើសុំជំនួយបច្ចេកទេសពីនាយកដ្ឋាន សហគមន៍ តំបន់ការពារធម្មជាតិ តាមរយៈនាយកតំបន់ការពារធម្មជាតិ ក្នុងការរៀបចំកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។

ខ- សហគមន៍តំបន់ការពារធម្មជាតិ ត្រូវរៀបចំកិច្ចប្រជុំពិភាក្សាដោយមានការឯកភាពលើសេចក្តីព្រាងកិច្ចព្រមព្រៀង ស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។

គ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើការពិគ្រោះយោបល់លើកិច្ចព្រមព្រៀងជាមួយនាយកតំបន់ការពារធម្មជាតិ។

ឃ-សហគមន៍តំបន់ការពារធម្មជាតិ ត្រូវប្រជុំផ្សព្វផ្សាយដល់សមាជិក លើសេចក្តីព្រាងនៃកិច្ចព្រមព្រៀង។

ង- ទម្រង់គំរូនៃកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិ មានក្នុងឧបសម្ព័ន្ធទី៥ ។

## ៧-២ ពិធីចុះកិច្ចព្រមព្រៀង

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើសេចក្តីថ្លែងហេតុសុំការចុះកិច្ចព្រមព្រៀងជាមួយ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ។

ខ- ទីកន្លែងពិធីចុះកិច្ចព្រមព្រៀង អាចធ្វើនៅសហគមន៍មូលដ្ឋាន ឬធ្វើនៅទីស្នាក់ការតំបន់ការពារធម្មជាតិ អាស្រ័យលើស្ថានភាពសមស្រប និងការឯកភាពរវាងភាគីទាំងពីរ។

គ- ពិធីចុះកិច្ចព្រមព្រៀង ត្រូវមានការចូលរួមពីសមាជិកសហគមន៍និងមានសាក្សីដឹងឮ ពីអាជ្ញាធរដែនដី និងថ្នាក់ដឹកនាំក្រសួងបរិស្ថាន។

ឃ-ឯកសារនៃកិច្ចព្រមព្រៀង ស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវតម្កល់ទុកក្នុងសហគមន៍ ស្ថាប័នដែលបានចុះហត្ថលេខា និងនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ ។

# ជំហានទី ៨
# យន្តការត្រួតពិនិត្យ និងវាយតម្លៃ

## ៨-១ ក្របខ័ណ្ឌសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ

ក- ការត្រួតពិនិត្យលើសកម្មភាពគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ ធ្វើឡើង ដោយឈរលើលក្ខខណ្ឌបួនជាមូលដ្ឋានសម្រាប់ការវាយតម្លៃពី

ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រកបដោយចីរភាព។ លក្ខខណ្ឌទាំងបួននោះរួមមាន ៖

**លក្ខខណ្ឌទី១ ធនធានធម្មជាតិត្រូវបានថែរក្សា** ៖ មានន័យថា ក្រោយពីរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ធនធានធម្មជាតិក្នុងតំបន់នោះមានការថែរក្សា និងគ្រប់គ្រងច្បាស់លាស់។ លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃលើលក្ខខណ្ឌទី១ មាន៖

- មានការកំណត់តំបន់គ្រប់គ្រង និងប្រើប្រាស់បានច្បាស់លាស់
- ជីវចម្រុះត្រូវបានថែរក្សា និងការពារ
- ធនធានធម្មជាតិក្នុងតំបន់ព្រៃសហគមន៍មានការកែលម្អ
- ការដកហូត និងប្រើប្រាស់ធនធានធម្មជាតិមានលក្ខណៈសមស្រប។

**លក្ខខណ្ឌទី២ សុខុមាលភាពសមាជិកត្រូវបានធ្វើឱ្យប្រសើរឡើង** ៖ មានន័យថា ក្រោយពីរៀបចំសហគមន៍តំបន់ការពារធម្មជាតិ សមាជិកសហគមន៍បានប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នោះ សម្រាប់ការដោះស្រាយជីវភាពបានប្រសើរជាងមុន។ លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃលើលក្ខខណ្ឌទី២ មាន៖

- សមាជិកសហគមន៍ មានសិទ្ធិក្នុងការប្រើប្រាស់ធនធានធម្មជាតិ
- ធនធានធម្មជាតិក្នុងតំបន់សហគមន៍ បានរួមចំណែកផ្តល់ប្រាក់ចំណូល
- ទ្រទ្រង់ជីវភាព
- ព្រៃសហគមន៍បានរួមចំណែកជួយដល់ផ្នែកកសិកម្ម
- សមាជិកសហគមន៍មានឱកាសទទួលបានមុខរបរបន្ថែមផ្សេងៗ។

**លក្ខខណ្ឌទី៣ សុខុមាលភាពសហគមន៍ត្រូវបានធានា៖** មានន័យថា ក្រោយពីបានរៀបចំសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ទទួលបានផលប្រយោជន៍ពីការចូលរួមគ្រប់គ្រងប្រកបដោយ សមធម៌ មានសមត្ថភាព និងមានភាពជាម្ចាស់ក្នុងការគ្រប់គ្រង។ លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃលើលក្ខខណ្ឌទី៣ មាន៖

- ប្រព័ន្ធគ្រប់គ្រងសហគមន៍បង្កើតឡើងដោយមានការចូលរួមពីសមាជិក
- យន្តការគ្រប់គ្រង និងការដោះស្រាយទំនាស់ប្រកបដោយប្រសិទ្ធភាព
- គណៈកម្មការមានសមត្ថភាពដឹកនាំ
- តម្លាភាពក្នុងការគ្រប់គ្រង ។

**លក្ខខណ្ឌទី៤ ការគាំទ្រពីមជ្ឈដ្ឋានខាងក្រៅ** ៖ មានន័យថា សហគមន៍តំបន់ការពារធម្មជាតិមានការគាំទ្រពីផ្នែកគោលនយោបាយ ច្បាប់ បច្ចេកទេសពីស្ថាប័នជំនាញ អាជ្ញាធរដែនដីនិងដៃគូអភិវឌ្ឍន៍នានា។ លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃលើលក្ខខណ្ឌទី៤ មាន៖

- អ្នកពាក់ព័ន្ធចូលរួម និងគាំទ្រដល់ការគ្រប់គ្រងរបស់សហគមន៍
- គោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍសហគមន៍
- ការអប់រំ ផ្សព្វផ្សាយក្នុង និងក្រៅប្រព័ន្ធ គាំទ្រដល់ការចូលរួមគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍។

ខ- ផ្អែកលើលក្ខខណ្ឌទាំងបួន និងលក្ខណៈវិនិច្ឆ័យ អ្នកសម្របសម្រួលនិងគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើការពិភាក្សាកំណត់សូចនាករក្នុងពេលរៀបចំផែនការគ្រប់គ្រងស្របទៅតាមស្ថានភាពជាក់ស្តែងរបស់សហគមន៍តំបន់ការពារធម្មជាតិនីមួយៗ។

គ- ទម្រង់គំរូនៃក្របខ័ណ្ឌសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ ការគ្រប់គ្រងរបស់សហគមន៍ តំបន់ការពារធម្មជាតិ មានក្នុងឧបសម្ព័ន្ធទី៦ ។

## ៨-២ ការត្រួតពិនិត្យ និងវាយតម្លៃ

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើការប្រជុំវាយតម្លៃពីសកម្មភាពអនុវត្ត ស្របតាមលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ។

ខ- សមាជិកសហគមន៍តំបន់ការពារធម្មជាតិ ត្រូវចូលរួមធ្វើការត្រួតពិនិត្យ និងវាយតម្លៃ លើសកម្មភាពអនុវត្តតាមរយៈកិច្ចប្រជុំប្រចាំឆ្នាំរបស់សហគមន៍។

គ- នាយកតំបន់ការពារធម្មជាតិ ត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃ លើការអនុវត្តផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ ជារៀងរាល់ឆ្នាំ ឬមុនពេលកំណត់ក្នុងករណីចាំបាច់។

ឃ-នាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើការពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងរៀងរាល់បី(៣)ឆ្នាំម្តង ឬមុនពេលកំណត់ក្នុងករណីចាំបាច់។

ង- ការត្រួតពិនិត្យ និងវាយតម្លៃ ត្រូវធ្វើឡើងដោយមានការចូលរួមពីសហគមន៍តំបន់ការ ពារធម្មជាតិ ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ទីរបរិស្ថាន នាយកតំបន់ការពារធម្មជាតិ ឬដៃគូអភិវឌ្ឍន៍។

## ៨-៣ ការរៀបចំរបាយការណ៍

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវរៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំផ្ញើរជូននាយកតំបន់ការពារធម្មជាតិ និងចម្លងជូនមេឃុំ ចៅសង្កាត់ និងអភិបាលស្រុក ក្រុង។

ខ- ខ្លឹមសារនៃរបាយការណ៍ ត្រូវបង្ហាញអំពីសកម្មភាព លទ្ធផលសម្រេចបានថវិកា ចំណូលចំណាយ បញ្ហាជួបប្រទះ ទិសដៅអនុវត្ត និងសំណូមពរ។

គ- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវរក្សាទុកនិងគ្រប់គ្រងរបាយការណ៍ទិន្នន័យឱ្យបានត្រឹមត្រូវ។

ឃ-ទម្រង់គំរូនៃរបាយការណ៍ប្រចាំត្រីមាស មាននៅក្នុងឧបសម្ព័ន្ធទី៧។

## ផ្នែកឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ ទម្រង់គំរូ ពាក្យសុំចូលសមាជិកសហគមន៍តំបន់ការពារធម្មជាតិ

ឧបសម្ព័ន្ធទី២ ៖ ទម្រង់គំរូ លិខិតស្នើសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

ឧបសម្ព័ន្ធទី៣ ៖ ទម្រង់គំរូ លក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ

ឧបសម្ព័ន្ធទី៤ ៖ ទម្រង់គំរូ ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

ឧបសម្ព័ន្ធទី៥ ៖ ទម្រង់គំរូ កិច្ចព្រមព្រៀង ស្តីពី ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

ឧបសម្ព័ន្ធទី៦ ៖ ទម្រង់គំរូ ក្របខ័ណ្ឌសម្រាប់ ការត្រួតពិនិត្យ និងវាយតម្លៃ

ឧបសម្ព័ន្ធទី៧ ៖ ទម្រង់គំរូ របាយការណ៍ត្រីមាសសម្រាប់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ

## ឧបសម្ព័ន្ធទី ១ ៖ ទម្រង់គំរូពាក្យសុំចូលសមាជិកសហគមន៍តំបន់ការពារធម្មជាតិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៙៛

## ពាក្យសុំចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ .....................ភេទ..........អាយុ..........ជនជាតិ........សញ្ជាតិ.........
ទីកន្លែងកំណើត ភូមិ.......................ឃុំ..................ស្រុក..............ខេត្ត.....................
ទីលំនៅបច្ចុប្បន្នក្រុមទី................ភូមិ..................ឃុំ .....................ស្រុក...................
ខេត្ត..........ជាមេគ្រួសារដែលមានសមាជិកសរុបចំនួន.........នាក់ (ស្រី........ប្រុស..........)។

**<u>សូមគោរពជូន</u>**

**លោកប្រធានគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ**

**កម្មវត្ថុ** :សុំចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ.................................

**មូលហេតុ** : .......................................................................................

ន័យដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងមូលហេតុខាងលើ សូមលោកប្រធានគណៈកម្មការ មេត្តាអនុញ្ញាតឱ្យគ្រួសារខ្ញុំបាទ-នាងខ្ញុំ បានចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ.................ដោយសេចក្តីអនុគ្រោះ ។

ខ្ញុំសូមសន្យាថានឹងចូលរួមគ្រប់សកម្មភាព ក្នុងដំណើរការរៀបចំ និងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ព្រមទាំងគោរពនិងអនុវត្តតាមលក្ខន្តិកៈរបស់សហគមន៍។

សូមលោកប្រធានមេត្តាទទួលនូវសេចក្តីគោរពរាប់អានអំពីខ្ញុំបាទ- នាងខ្ញុំ ។

...................ថ្ងៃទី..........ខែ..............ឆ្នាំ២០...

**ស្នាមមេដៃស្តាំអ្នកស្នើសុំ**

បានឃើញនិងឯកភាព

................ថ្ងៃទី..........ខែ............ឆ្នាំ២០........

**តំណាង/គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ**

..................................................................

បានឃើញនិងបញ្ជាក់ថា

ឈ្មោះ......................ពិតជារស់នៅក្នុងភូមិនេះប្រាកដមែន។

............ថ្ងៃទី..........ខែ............ឆ្នាំ២០....

**មេភូមិ**

**ឧបសម្ព័ន្ធទី២** : **ទម្រង់គំរូ លិខិតស្នើសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៦៣❋៤៤

## លិខិតស្នើសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

យើងខ្ញុំជាតំណាងឱ្យប្រជាពលរដ្ឋចំនួន........គ្រួសារ រស់នៅភូមិ...........ឃុំ............. ស្រុក...............ខេត្ត....................នៃដែនជម្រកសត្វព្រៃ/ឧទ្យានជាតិ.........................។

<u>**សូមគោរពជូន**</u>

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**

*ជាទីគោរព !*

**តាមរយៈ** ៖ - លោកមេឃុំ.......................................................................................

- លោកនាយកតំបន់ការពារធម្មជាតិ..................................................
- លោកអភិបាលនៃគណៈអភិបាលស្រុក/ក្រុង.....................................
- លោកប្រធានមន្ទីរបរិស្ថានខេត្ត.......................................................
- ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត..........................................
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ

**កម្មវត្ថុ** ៖ សំណើសុំអនុញ្ញាតរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ស្ថិតក្នុងតំបន់ការពារធម្មជាតិ............................ដែលមានទំហំផ្ទៃដីសរុបចំនួន..............ហិកតា ស្ថិតនៅឃុំ..................ស្រុក........................ខេត្ត..............................។

**យោង** ៖ ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយសសូមគោរពជូន**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន** មេត្តាជ្រាបថា (បង្ហាញពីគោលបំណងជាក់លាក់...........) ដើម្បីចូលរួមចំណែកក្នុងការគ្រប់គ្រង ថែរក្សាការពារ និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនិងរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ស្របតាមគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

យើងខ្ញុំសុំអនុញ្ញាតរៀបចំសហគមន៍តំបន់ការពារធម្មជាតិក្នុងតំបន់ការពារធម្មជាតិ...................ដែលមានទំហំផ្ទៃដីសរុបចំនួន.................ហិកតា ស្ថិតនៅឃុំ.....................ស្រុក..................ខេត្ត.................។ យើងខ្ញុំសូមអនុវត្តតាមលិខិតបទដ្ឋានច្បាប់ និងគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម**ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពអំពីយើងខ្ញុំ។

**សូមភ្ជាប់មកជាមួយនូវ ៖**

- បញ្ជីឈ្មោះ និងស្នាមមេដៃប្រជាពលរដ្ឋស្នើសុំ
- ផែនទីតំបន់ព្រៃសហគមន៍តំបន់ការពារធម្មជាតិ

ធ្វើនៅ...............ថ្ងៃទី..........ខែ...........ឆ្នាំ២០....

**ស្នាមមេដៃតំណាងប្រជាពលរដ្ឋ**

ឈ្មោះ.................... ឈ្មោះ................... ឈ្មោះ................... ឈ្មោះ......................

លេខ.............

បានឃើញនិងគោរពជូន

លោកនាយកតំបន់ការពារធម្មជាតិ..
...............

ដើម្បីពិនិត្យនិងជួយសម្រួល

.............ថ្ងៃទី.......ខែ.......ឆ្នាំ២០. ..

**មេឃុំ/ចៅសង្កាត់**

លេខ...............

បានឃើញនិងគោរពជូន

លោកអភិបាលនៃគណៈអភិបាលស្រុក............

ដើម្បីពិនិត្យនិងជួយសម្រួល

.............ថ្ងៃទី.......ខែ.......ឆ្នាំ២០...

**នាយកតំបន់ការពារធម្មជាតិ**.........

លេខ.............

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរបរិស្ថានខេត្ត.......

.........

ដើម្បីពិនិត្យនិងជួយសម្រួល

.............ថ្ងៃទី......ខែ......ឆ្នាំ២០...

**អភិបាលស្រុក/ក្រុង**

លេខ...............

បានឃើញនិងគោរពជូន

ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត.............

ដើម្បីពិនិត្យនិងជួយសម្រួល

.............ថ្ងៃទី......ខែ......ឆ្នាំ២០...

**ប្រធានមន្ទីរបរិស្ថាន**

លេខ.............

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកជាអគ្គនាយក

នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិ

ងអភិរក្សធម្មជាតិ

ដើម្បីពិនិត្យនិងជួយសម្រួល

.............ថ្ងៃទី.........ខែ.......ឆ្នាំ២

០...

**អភិបាលខេត្ត**

លេខ.............

បានឃើញនិងគោរពជូន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន

ដើម្បីពិនិត្យនិងសម្រេច

រាជធានីភ្នំពេញ ថ្ងៃទី........ខែ..........ឆ្នាំ២០...

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋា**

**នរដ្ឋបាលការពារនិង**

**អភិរក្សធម្មជាតិ**

លេខ................

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០...

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ឧបសម្ព័ន្ធទី៣ ៖ ទម្រង់គំរូ លក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៙៛

# លក្ខន្តិកៈ

# សហគមន៍តំបន់ការពារធម្មជាតិ...............................................

ភូមិ.....................ឃុំ.................ស្រុក.......................ខេត្ត.................

(ឆ្នាំ២០.....)

**សេចក្តីផ្តើម**

ប្រវត្តិសហគមន៍.........................................................................................

ដំណើរការរៀបចំលក្ខន្តិកៈ..............................................................................

## ជំពូក ១
## គោលបំណង

ប្រការ ១ ៖ ការរៀបចំលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ក្នុងគោលបំណង ៖

- ចូលរួមថែរក្សាការពារធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ ដើម្បីធានានូវការផ្គត់ផ្គង់ធនធានធម្មជាតិដល់សហគមន៍មូលដ្ឋាន ក្នុងការប្រើប្រាស់ធនធានធម្មជាតិឱ្យមានចីរភាពទាំងបច្ចុប្បន្ននិងសម្រាប់កូន ចៅជំនាន់ក្រោយ
- ធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិក្នុងតំបន់ ដើម្បីរក្សាបាននូវលំនឹងធម្មជាតិ
- ចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលលើការការពារ និងថែរក្សាធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន សំដៅរួមចំណែកបង្កើនជីវភាពរបស់សហគមន៍មូលដ្ឋាន( សហគមន៍អាចកំណត់គោលបំណងជាក់លាក់បន្ថែមទៀតទៅតាមស្ថានភាពសហគមន៍នីមួយៗ )។

## ជំពូក ២
## បទប្បញ្ញត្តិទូទៅ

ប្រការ ២ ៖ សហគមន៍តំបន់ការពារធម្មជាតិ..............................រៀបចំឡើងដោយមានការឯកភាពគ្នាពីប្រជាពលរដ្ឋក្នុងភូមិ..................មិនបម្រើឱ្យបុគ្គលណាម្នាក់ ឬគណបក្សនយោបាយណាមួយឡើយ និងត្រូវគោរពទៅតាមច្បាប់របស់រដ្ឋ ។

ប្រការ ៣ ៖ ធនធានធម្មជាតិដែលមានក្នុងតំបន់សហគមន៍ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍ ដោយមានការជួយសម្របសម្រួលពីនាយកតំបន់ការពារធម្មជាតិ ក្រុមប្រឹក្សាឃុំ/សង្កាត់ ស្រុក/ក្រុង និងមន្ទីរបរិស្ថាន ។

ប្រការ ៤ ៖ ផ្ទៃដីសហគមន៍តំបន់ការពារធម្មជាតិ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងប្រើប្រាស់ជាលក្ខណៈសហគមន៍ ស្របតាមមាត្រា ២៦ នៃច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ។

ប្រការ ៥ ៖ រាល់ការដឹកជញ្ជូនផល អនុផលព្រៃឈើ និងធនធានជលផល ដែលឆ្លងកាត់ក្នុងតំបន់ព្រៃសហគមន៍ត្រូវស្ថិតនៅក្រោម ការត្រួតពិនិត្យរបស់សហគមន៍ ដោយរាយការណ៍ជូនស្ថាប័នជំនាញក្នុងមូលដ្ឋាន។

ប្រការ ៦ ៖ សមាជិកសហគមន៍មានកាតព្វកិច្ចចូលរួមរាល់សកម្មភាពផ្សេងៗក្នុងសហគមន៍។

ប្រការ ៧ ៖ លក្ខន្តិកៈនេះអនុវត្តបានតែនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ.......ប៉ុណ្ណោះ។

## ជំពូក ៣
## ឈ្មោះ និងទីតាំងសហគមន៍តំបន់ការពារធម្មជាតិ

ប្រការ ៨ ៖ សហគមន៍មានឈ្មោះថាសហគមន៍តំបន់ការពារធម្មជាតិ...............ដែលមាន ការចូលរួមដោយស្ម័គ្រចិត្តពីប្រជាពលរដ្ឋស្ថិតក្នុងភូមិ...........ឃុំ/សង្កាត់........ ស្រុក/ក្រុង........ខេត្ត............។ សហគមន៍មានសមាជិកចំនួន..........គ្រួសារ ចំនួនមនុស្ស......................ស្រី...............នាក់។

ប្រការ ៩ ៖ ទំហំផ្ទៃដីសហគមន៍តំបន់ការពារធម្មជាតិ..........មានទំហំ................ហិកតា ដែលមាន ទីតាំងព្រំប្រទល់ ៖
ខាងជើង..........................................................................................
ខាងត្បូង..........................................................................................
ខាងកើត..........................................................................................
ខាងលិច..........................................................................................
ដូចមាននិយាមកាក្នុងតារាងខាងក្រោម៖

| ចំណុច | ឈ្មោះអ្នកភូមិហៅ | អាប់ស៊ីស X | អរដោនេ Y |
|---|---|---|---|
| A | ឧ. ចំបក់កោង | | |
| B | | | |
| C | | | |
| D | | | |
| E | | | |
| F | | | |
| G | | | |

| | | | |
|---|---|---|---|
| H | | | |

## ជំពូក ៤
## លក្ខខណ្ឌនៃការសុំចូលជាសមាជិក និងការលាឈប់

ប្រការ ១០ ៖ ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលរស់ក្នុងភូមិ........ឃុំ/សង្កាត់.....ស្រុក/ក្រុង.........ខេត្ត.......មានសិទ្ធិសុំចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ "....."។

ប្រការ ១១ ៖ មេគ្រួសារដែលមានបំណងចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិត្រូវបំពេញពាក្យសុំចូលជាសមាជិក ដោយមានការទទួលស្គាល់ពីមេភូមិ ។

ប្រការ ១២ ៖ អ្នកដែលមានសិទ្ធិចូលជាសមាជិកសហគមន៍បានលុះត្រាតែ ៖
- ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិជាអចិន្ត្រៃយ៍
- គ្រួសារមកតាំងទីលំនៅដ្ឋានថ្មី ត្រូវមានការបញ្ជាក់ពីមេភូមិ ស្របតាមច្បាប់ ។

ប្រការ ១៣ ៖ សមាជិកសហគមន៍តំបន់ការពារធម្មជាតិ.............ដែលមានបំណងលាឈប់ត្រូវធ្វើលិខិតជាលាយលក្ខ័អក្សរដោយមិនត្រូវទាមទារអ្វីមួយពីសហគមន៍ឡើយ។

## ជំពូក ៥
## រចនាសម្ព័ន្ធ តួនាទី និងសិទ្ធិ

ប្រការ ១៤ ៖ រចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ..........មានពីរ/បីលំដាប់ថ្នាក់ គឺ ថ្នាក់ក្រុម និងថ្នាក់អនុគណៈកម្មការ/គណៈកម្មការ អមដោយទីប្រឹក្សា និងអ្នកគាំទ្រ ។

ក. ថ្នាក់ក្រុមមានចំនួនបីរូប គឺប្រធាន ១រូប និងអនុប្រធាន ២រូប
ខ. ថ្នាក់អនុគណៈកម្មការមានចំនួន៣រូប ក្នុងនោះមានស្ត្រី ១រូប
គ. ថ្នាក់គណៈកម្មការមានចំនួនពី៥ ទៅ ១១រូប ក្នុងនោះមានស្ត្រី ២ ទៅ ៣រូប។
(កំណត់យកទម្រង់ណាមួយអាស្រ័យលើសហគមន៍)

### ករណីការចូលរួម១ភូមិ



## ករណីការចូលរួមចាប់ពី២ភូមិឡើង




ប្រការ ១៥ ៖ ការជ្រើសរើសប្រធានក្រុម ត្រូវជ្រើសរើស ដោយសមាជិកនៅក្នុងក្រុម ។

ប្រការ ១៦ ៖ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ...............................ត្រូវបាន ជ្រើសរើសឡើងតាមរយៈការបោះឆ្នោតពីសមាជិកនៅក្នុងសហគមន៍។

ប្រការ ១៧ ៖ អាណត្តិរបស់ប្រធានក្រុម និងគណៈកម្មការសហគមន៍មានរយៈពេល ៥ឆ្នាំ។

ប្រការ ១៨ ៖ ក្នុងករណីមានភាពអសកម្ម ឬមានការលាលែងរបស់គណៈកម្មការឬប្រធានក្រុម សហគមន៍ត្រូវជ្រើសរើសយកអ្នកដែលមានសំឡេងបន្ទាប់ ឬតាមរយៈការបោះឆ្នោតដោយឡែក។

ប្រការ ១៩ ៖ តួនាទី និងសិទ្ធិរបស់សមាជិកសហគមន៍តំបន់ការពារធម្មជាតិ
- ចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធដើម្បីការពារធនធានធម្មជាតិ ក្នុងនិងក្រៅតំបន់សហគមន៍
- ជួយណែនាំផ្សព្វផ្សាយដល់សមាជិកសហគមន៍ និងអ្នកមកពីក្រៅ
- ចូលរួមអនុវត្តន៍ការងារសហគមន៍តំបន់ការពារធម្មជាតិ
- ផ្តល់ព័ត៌មានអំពីបទល្មើស និងអ្នកប្រព្រឹត្តដល់គណៈកម្មការសហគមន៍
- មានសិទ្ធិប្រើប្រាស់ធនធានធម្មជាតិស្របទៅតាមលក្ខន្តិកៈនិងផែនការគ្រប់គ្រង របស់សហគមន៍តំបន់ការពារធម្មជាតិ
- គោរព និងអនុវត្តទៅតាមលក្ខន្តិកៈរបស់សហគមន៍
- បង់ប្រាក់ភាគទាន.................រៀលក្នុងមួយខែ ក្នុងមួយគ្រួសារ ដើម្បីជួយសម្រួលដល់ដំណើរការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ

- មានសិទ្ធិសុំចេញពីសមាជិកសហគមន៍តំបន់ការពារធម្មជាតិ ស្របតាមប្រការ១៣ នៃលក្ខន្តិកៈ

ប្រការ ២០ ៖ តួនាទី និងសិទ្ធិរបស់ប្រធានក្រុម

- គោរព អនុវត្តទៅតាមលក្ខន្តិកៈ និងផែនការគ្រប់គ្រងសហគមន៍
- ដឹកនាំការងារនៅក្នុងក្រុមឱ្យបានល្អ
- ទំនាក់ទំនងការងារជាមួយគណៈកម្មការសហគមន៍
- ផ្សព្វផ្សាយលក្ខន្តិកៈដល់សមាជិកក្នុងក្រុម (ភូមិ)
- ណែនាំដល់អ្នកប្រព្រឹត្តខុសពីលក្ខន្តិកៈ
- រាយការណ៍ពីអ្នកប្រព្រឹត្តផ្ទុយពីលក្ខន្តិកៈ ដល់គណៈកម្មការសហគមន៍
- សម្រួល និងចុះហត្ថលេខា លើពាក្យស្នើសុំរបស់សមាជិក
- ប្រមូលភាគទានពីសមាជិកក្នុងក្រុម ដើម្បីចូលមូលនិធិសហគមន៍
- ចូលរួមប្រជុំ ត្រួតពិនិត្យ និងវាយតម្លៃការងារសហគមន៍ ។

ប្រការ ២១ ៖ តួនាទី និងសិទ្ធិរបស់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ

- **ប្រធានគណៈកម្មការ ៖**
  - ដឹកនាំអនុវត្តការងារ និងជួយសម្របសម្រួលដោះស្រាយបញ្ហាកើតមានឡើងនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ
  - ទំនាក់ទំនង និងសហការជាមួយ អាជ្ញាធរដែនដី នាយកតំបន់ការពារធម្មជាតិ មន្ទីរបរិស្ថាន ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ដើម្បីរកជំនួយគាំទ្រដល់ដំណើរការគ្រប់គ្រងរបស់សហគមន៍ ។
- **អនុប្រធាន២រូប ៖**
  - ជំនួសមុខឱ្យប្រធាននៅពេលដែលប្រធានអវត្តមាន
- **ហិរញ្ញឹក ១រូប ៖**
  - គ្រប់គ្រងថវិការបស់សហគមន៍តំបន់ការពារធម្មជាតិ
  - កត់ត្រានិងធ្វើរបាយការណ៍ចំណូលចំណាយឱ្យបានត្រឹមត្រូវជូនគណៈកម្មការ និងសមាជិកសហគមន៍រៀងរាល់ពេលប្រជុំ។
- **លេខាធិការ ២ រូប ៖**
  - រៀបចំ និងគ្រប់គ្រងឯកសារផ្សេងៗ
  - ធ្វើកំណត់ហេតុប្រជុំ
- **ផ្នែកល្បាត ១រូប ៖**

- ចាត់ចែងការត្រួតពិនិត្យ
- ចូលរួមត្រួតពិនិត្យក្នុងសហគមន៍តំបន់ការពារធម្មជាតិ
- សហការទប់ស្កាត់នូវរាល់សកម្មភាព និងរាយការណ៍នូវរាល់បទល្មើសដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ........................................... ។

(ការកំណត់តួនាទី សហគមន៍អាចបន្ថែមស្របតាមស្ថានភាពជាក់ស្តែង)

ប្រការ ២២ ៖ សមាសភាព តួនាទី និងសិទ្ធិរបស់ទីប្រឹក្សា៖ ទីប្រឹក្សាសហគមន៍អាចជា ក្រុមប្រឹក្សាឃុំ គ្រូបង្រៀន គណៈកម្មការវត្ត ចាស់ទុំ ឬព្រះសង្ឃ ដែលមានតួនាទីដូចខាងក្រោម៖

- ផ្តល់យោបល់ដល់គណៈកម្មការ ក្នុងដំណើរការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ
- ជួយសម្របសម្រួល និងដោះស្រាយបញ្ហា តាមសំណើរបស់គណៈកម្មការទំនាក់ទំនងនិងផ្សព្វផ្សាយពីសកម្មភាពសហគមន៍ដល់ស្ថាប័នពាក់ព័ន្ធដៃគូអភិវឌ្ឍន៍
- ចូលរួមត្រួតពិនិត្យ វាយតម្លៃ និងតម្រង់ទិសការងារសហគមន៍។

ប្រការ ២៣ ៖ សមាសភាព តួនាទី និងសិទ្ធិអ្នកគាំទ្រ ៖ មន្ទីរបរិស្ថាន នាយកតំបន់ការពារធម្មជាតិ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ដែលមានតួនាទី ដូចខាងក្រោម៖

- ជួយសម្របសម្រួលក្នុងការធ្វើសេចក្តីសម្រេចផ្សេងៗរបស់សហគមន៍
- ជួយទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី ដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយគាំទ្រដល់ដំណើរការគ្រប់គ្រងសហគមន៍
- ជួយផ្សព្វផ្សាយដល់សហគមន៍ក្នុងការអនុវត្តច្បាប់ដែលពាក់ព័ន្ធទៅនឹងតំបន់ការពារធម្មជាតិ
- ផ្តល់ចំណេះដឹង បច្ចេកទេស បទពិសោធន៍ និងព័ត៌មានផ្សេងៗដល់សហគមន៍
- ជួយសម្របសម្រួលក្នុងការរៀបចំផែនការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ ។

## **ជំពូក ៦**

## កិច្ចប្រជុំ និងការសម្រេចចិត្ត

ប្រការ ២៤ ៖ ប្រធានគណៈកម្មការសហគមន៍ មានតួនាទីដឹកនាំកិច្ចប្រជុំការងារសហគមន៍តំបន់ការពារធម្មជាតិ ។

ប្រការ ២៥ ៖ ប្រធានក្រុមគណៈកម្មការ និងទីប្រឹក្សា ត្រូវជួបប្រជុំគ្នារៀងរាល់..........ខែម្តង ដោយកំណត់យក................... នៅពេលព្រឹក/ល្ងាច ។

ប្រការ ២៦ ៖ ប្រសិនបើមានករណីចាំបាច់ គណៈកម្មការសហគមន៍អាចរៀបចំកិច្ចប្រជុំមុនពេលកំណត់ ។

ប្រការ ២៧ ៖ សមាជិកសហគមន៍ត្រូវមានការប្រជុំ.......................ដងក្នុងមួយឆ្នាំ ៖
ក. ប្រជុំលើកទី ១ នៅក្នុងខែ.....................................................
ខ. ប្រជុំលើកទី ២ នៅក្នុងខែ.....................................................

ប្រការ ២៨ ៖ ប្រធានគណៈកម្មការសហគមន៍ មានសិទ្ធិសម្រេច................................ ។ លើសពីនេះត្រូវធ្វើការសម្រេចចិត្ត ដោយសម្លេង២/៣ នៃចំនួនសមាជិកសហគមន៍តំបន់ការពារធម្មជាតិ។

## ជំពូក ៧
## គោលការណ៍ដកហូត និងប្រើប្រាស់ធនធានធម្មជាតិ

ប្រការ ២៩ ៖ ការដកហូតផល អនុផលព្រៃឈើ និងធនធានជលផលសម្រាប់ប្រើប្រាស់ជាលក្ខណៈគ្រួសារ និងសហគមន៍ត្រូវអនុវត្តស្របតាមផែនការគ្រប់គ្រងរបស់សហគមន៍ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

ប្រការ ៣០ ៖ ការដកហូតផលឈើសម្រាប់ប្រើប្រាស់ជាលក្ខណៈគ្រួសារ ត្រូវសុំការអនុញ្ញាតពីគណៈកម្មការសហគមន៍ និងមានការឯកភាពីនាយកតំបន់ការពារធម្មជាតិ។

ប្រការ ៣១ ៖ ការដកហូត.................................ត្រូវធ្វើពាក្យសុំជាលាយល័ក្ខអក្សរ ដោយបញ្ជាក់ពីពេលវេលាទីតាំង ទំហំ និងចំនួនឱ្យបានច្បាស់លាស់ ។

ប្រការ ៣២ ៖ ប្រជាពលរដ្ឋក្នុងភូមិ ដែលមិនមែនជាសមាជិកសហគមន៍ និងអ្នកភូមិជិតខាងអាចអនុញ្ញាត ឬមិនអនុញ្ញាត............................................. (ស្របតាមស្ថានភាពរបស់សហគមន៍នីមួយៗ) ។

ប្រការ ៣៣ ៖ ការដកហូត...................សម្រាប់បម្រើផលប្រយោជន៍នៅក្នុងសហគមន៍ ត្រូវមានការឯកភាពពីសមាជិកសហគមន៍ និងមានលិខិតអនុញ្ញាតពីនាយកតំបន់ការពារធម្មជាតិ.................និងស្របទៅតាមផែនការគ្រប់គ្រងសហគមន៍។

## ជំពូក ៨
## គោលការណ៍ហាមឃាត់

ប្រការ ៣៤ ៖ ហាមគៀរដើមឈើ កាប់រុករានដីព្រៃសហគមន៍តំបន់ការពារធម្មជាតិ..........។

ប្រការ ៣៥ ៖ ហាមរាល់ការលក់ ដូល ប្រវាស់ ឬបែងចែកជាលក្ខណៈគ្រួសារ ។

ប្រការ ៣៦ ៖ ហាមបរបាញ់ឬចាប់សត្វព្រៃនៅក្នុង និងក្រៅតំបន់ព្រៃសហគមន៍តាមគ្រប់មធ្យោបាយទាំងអស់។

ប្រការ ៣៧ ៖ ហាមកាប់ដើមឈើដែលមានដោយកម្រ មានដូចជា...............................។

ប្រការ ៣៨ ៖ ហាមកាប់ប្រភេទឈើផ្តល់ជ័រ ដូចជា ដើមស្រល់ ដើមឈើទាល ដើមត្រាច ដើមជ័រចុង..........។

ប្រការ ៣៩ ៖ ហាមបង្កើតឡជ្យូងនៅក្នុង ឬក្បែរតំបន់ព្រៃសហគមន៍ ។

ប្រការ ៤០ ៖ ហាមកាប់រំលំដើម ដើម្បីប្រមូលផ្លែឈើព្រៃគ្រប់ប្រភេទ ។

ប្រការ ៤១ ៖ ហាមកាប់ឈើរស់ធ្វើអុស ឬធ្យូង ។

ប្រការ ៤២ ៖ ហាមកាប់ឈើរស់ធ្វើបង្គោលគ្រាក់ ដើម្បីធ្វើអាជីវកម្ម ។

ប្រការ ៤៣ ៖ ហាមនេសាទត្រីដោយប្រើប្រាស់ឧបករណ៍ខុសច្បាប់។( សហគមន៍អាចបន្ថែមការហាមឃាត់ ស្របតាមស្ថានភាពជាក់ស្តែង )

## ជំពូក ៩
## សំណងការខូចខាត

ប្រការ ៤៤ ៖ សហគមន៍អាចឃាត់បទល្មើសជាក់ស្តែងក្នុងព្រៃសហគមន៍ និងក្នុងតំបន់ការពារធម្មជាតិ ដោយបញ្ជូនទៅសមត្ថកិច្ចជំនាញនៅជិតបំផុត ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងមាត្រា៨៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ប្រការ ៤៥ ៖ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ អាចទាមទារសំណងខូចខាតពីបទល្មើសថ្នាក់ទី១ ស្របតាមមាត្រា៥៦ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

ប្រការ ៤៦ ៖ អ្នកដែលប្រព្រឹត្តផ្ទុយពីគោលការហាមឃាត់នៃលក្ខន្តិកៈ សហគមន៍តំបន់ការពារធម្មជាតិ............ត្រូវមានសំណងខូចខាតទៅតាមកម្រិត ដូចខាងក្រោម ៖

- **ការប្រព្រឹត្តខុសលើកទី១:** ត្រូវអប់រំណែនាំ និងធ្វើកិច្ចសន្យាជាលាយល័ក្ខអក្សរជាមួយសហគមន៍ ចំពោះវត្ថុតាងដែលជាផល អនុផលព្រៃឈើ ត្រូវរក្សាទុកប្រើប្រាស់ជាប្រយោជន៍សហគមន៍ រីឯវត្ថុតាង ដូចជា មធ្យោបាយ សម្ភារៈ គ្រឿងចក្រ។ល។ ត្រូវប្រគល់ឱ្យសមត្ថកិច្ចជំនាញដោយមានលិខិតប្រគល់-ទទួល និងកំណត់ហេតុបទល្មើសជាក់ស្តែង។
- **ការប្រព្រឹត្តខុសលើកទី ២:** ធ្វើកិច្ចសន្យាជាលាយល័ក្ខអក្សរជាមួយសហគមន៍ និងត្រូវសងការខូចខាតជាទឹកប្រាក់ស្មើនឹងពីរដងនៃតម្លៃខូចខាត ចំពោះវត្ថុតាងដែលជាផល អនុផលព្រៃឈើ ត្រូវរក្សាទុកប្រើប្រាស់ជាប្រយោជន៍សហគមន៍ រីឯវត្ថុតាង ដូចជា មធ្យោបាយ សម្ភារៈ គ្រឿងចក្រ។ល។ ត្រូវប្រគល់ឱ្យសមត្ថកិច្ចជំនាញដោយមានលិខិតប្រគល់-ទទួលនិងកំណត់ហេតុបទល្មើសជាក់ស្តែង ។
- **ការប្រព្រឹត្តខុសលើកទី៣:** ត្រូវសងការខូចខាតជាទឹកប្រាក់ស្មើនឹងបីដងនៃតម្លៃខូចខាតហើយត្រូវរឹបអូសវត្ថុតាងបញ្ជូនទៅសមត្ថកិច្ចជំនាញដោយមានលិខិតប្រគល់-ទទួល និងកំណត់ហេតុបទល្មើសជាក់ស្តែង ព្រមទាំងរៀបចំសំណុំបែបបទបញ្ជូនទៅតុលាការ ដើម្បីអនុវត្តតាមច្បាប់។

ប្រការ ៤៧ ៖ ការកាប់រានដីព្រៃក្នុងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើសំណងការខូចខាតជាទឹកប្រាក់ស្មើនឹង.................នៃតម្លៃខូចខាតជាក់ស្តែង និងដកហូតដីនោះទុកជាសម្បត្តិរបស់សហគមន៍វិញ។

ប្រការ ៤៨ ៖ ការចាប់សត្វគ្រប់ប្រភេទត្រូវសងការខូចខាតជាទឹកប្រាក់ស្មើនឹង.................នៃតម្លៃទីផ្សារ រីឯវត្ថុតាង....................បើសត្វងាប់...............។ បើសត្វរស់ត្រូវលែងក្នុងព្រៃសហគមន៍វិញ។

ប្រការ ៤៩ ៖ ការនេសាទដោយប្រើប្រាស់ឧបករណ៍ខុសច្បាប់ ត្រូវឃាត់ខ្លួនជនសង្ស័យ និងវត្ថុតាងបញ្ជូនទៅសមត្ថកិច្ចជំនាញដើម្បីអនុវត្តតាមច្បាប់ ។

ប្រការ ៥០ ៖ បទល្មើសកើតឡើងត្រូវរាយការណ៍ទៅនាយកតំបន់ការពារធម្មជាតិ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

ប្រការ ៥១ ៖ សមាជិកសហគមន៍ដែលឃុបឃិតក្នុងការប្រព្រឹត្តបទល្មើស ត្រូវធ្វើសំណងការខូចខាតជាទឹកប្រាក់ស្មើនឹង..................នៃតម្លៃខូចខាតជាក់ស្តែង និងត្រូវធ្វើកិច្ចសន្យាជាលាយល័ក្ខអក្សរជាមួយគណៈកម្មការសហគមន៍ ។

ប្រការ ៥២ ៖ សមាជិកសហគមន៍ដែលបានផ្តល់ព័ត៌មាន ឬចូលរួមក្នុងសកម្មភាពឃាត់ ចាប់បទល្មើសក្នុងព្រៃសហគមន៍តំបន់ការពារធម្មជាតិ និងក្នុងតំបន់តំបន់ការពារធម្មជាតិ នឹងត្រូវបានផ្តល់រង្វាន់លើកទឹកចិត្ត ស្របតាមមាត្រា៥៥ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

## ជំពូក ១០
## ការគ្រប់គ្រងថវិកា

ប្រការ ៥៣ ៖ ប្រភពប្រាក់ចំណូលរបស់សហគមន៍បានមកពី ៖

- ប្រាក់សំណងការខូចខាត
- ប្រាក់ភាគទានប្រចាំខែរបស់សមាជិកសហគមន៍
- ប្រាក់បានមកពីអ្នកចាប់អារម្មណ៍ សប្បុរសជន និងដៃគូអភិវឌ្ឍន៍
- ប្រាក់ចំណូលពីការលក់អនុផលព្រៃឈើ និងធនធានជលផល
- ប្រាក់ចំណូលពីសេវាអេកូទេសចរណ៍
- ប្រាក់មូលនិធិវេជបូក
- មូលនិធិឃុំ សង្កាត់
- មូលនិធិផ្សេងៗទៀត។

ប្រការ ៥៤ ៖ - គោលការណ៍ចំណាយថវិកាអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់តែការងារដែលបម្រើឱ្យផលប្រយោជន៍រួមរបស់សហគមន៍ និងសម្រាប់ជួយដល់ជនដែលងាយរងគ្រោះជាសមាជិកសហគមន៍។

ប្រការ ៥៥ ៖ គោលការណ៍គ្រប់គ្រងថវិកា

- ត្រូវមានតម្លាភាព និងស្របតាមនីតិវិធីហិរញ្ញវត្ថុ
- ហិរញ្ញឹកទទួលខុសត្រូវលើការគ្រប់គ្រងប្រាក់ចំណូល-ចំណាយ
- រាល់ការចំណាយក្រោមឬស្មើ.....រៀល ត្រូវមានការឯកភាពគណៈកម្មការ
- រាល់ការចំណាយលើសពី.................រៀល ត្រូវមានការឯកភាពពីទីប្រឹក្សា និងសហគមន៍។

# ជំពូក ១១
# អវសានលក្ខន្តិកៈ

ប្រការ ៥៦ ៖ សមាជិកសហគមន៍ ប្រធានក្រុម និងគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវចូលរួមអនុវត្តលក្ខន្តិកៈនេះ ។

ប្រការ ៥៧ ៖ លក្ខន្តិកៈនេះអាចធ្វើការកែសម្រួលបាន ដោយយោងទៅតាមភាពរីកចំរើន ឬការចាំបាច់របស់សហគមន៍ ។

ប្រការ ៥៨ ៖ លក្ខន្តិកៈនេះមានប្រសិទ្ធភាព និងជាគតិយុត្តិ ចាប់ពីក្រោយថ្ងៃប្រកាសជូនដំណឹងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

..........ថ្ងៃទី........ ខែ........ឆ្នាំ២០....

**ប្រធានគណៈកម្មការសហគមន៍**

...................................................

លេខ........................

បានឃើញនិងគោរពជូន

លោកនាយកតំបន់ការពារធម្មជាតិ.................

ដើម្បីពិនិត្យនិងជួយសម្រួល

..............ថ្ងៃទី.......ខែ.......ឆ្នាំ២០...

**មេឃុំ/ចៅសង្កាត់**

លេខ................

បានឃើញនិងគោរពជូន

លោកអភិបាលនៃគណៈអភិបាលស្រុក/ក្រុង............

ដើម្បីពិនិត្យនិងជួយសម្រួល

............ថ្ងៃទី.......ខែ.......ឆ្នាំ២០...

**នាយកតំបន់ការពារធម្មជាតិ**.........

លេខ.............

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរបរិស្ថានខេត្ត..........

ដើម្បីពិនិត្យនិងជួយសម្រួល

.............ថ្ងៃទី......ខែ......ឆ្នាំ២០...

**អភិបាលស្រុក/ក្រុង**

លេខ...............

បានឃើញនិងគោរពជូន

ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត.......

ដើម្បីពិនិត្យនិងសម្រេច

.............ថ្ងៃទី......ខែ......ឆ្នាំ២០...

**ប្រធានមន្ទីរបរិស្ថាន**

លេខ.....................

បានឃើញនិងឯកភាព

.............ថ្ងៃទី.........ខែ.......ឆ្នាំ២០...

**អភិបាលខេត្ត**

## ឧបសម្ព័ន្ធទី ៤: ឧទាហរណ៍គំរូ សម្រាប់ការសរសេរផែនការគ្រប់គ្រង សហគមន៍តំបន់ការពារធម្មជាតិ

### ១-សេចក្តីផ្តើម

- ប្រវត្តិសហគមន៍
- ទីតាំងភូមិសាស្ត្រ និងប្រជាសាស្ត្រ
- បញ្ហាទាក់ទងការប្រើប្រាស់ធនធានធម្មជាតិ
- ទស្សនៈវិស័យលើការគ្រប់គ្រងធនធានធម្មជាតិ

### ២-គោលបំណង

- លើកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង
- កំណត់នូវយុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវអនុវត្ត
- ប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនិងមានសមធម៌ក្នុងការបែងចែកផលប្រយោជន៍។

### ៣-ស្ថានភាពសេដ្ឋកិច្ចសង្គម

៣-១ ស្ថិតិសមាជិកសហគមន៍

៣-២ មុខរបរ និងកម្រិតជីវភាព

៣-៣ បញ្ហាជួបប្រទះ

### ៤-ស្ថានភាពទូទៅនៃធនធានធម្មជាតិ

៤-១ ប្រវត្តិនៃធនធានធម្មជាតិ( ធនធានព្រៃឈើ ឬធនធានជលផល )

៤-២ ទីតាំងនិងបរិមាណនៃធនធានធម្មជាតិក្នុងតំបន់ព្រៃសហគមន៍( លទ្ធផលសារពើភ័ណ្ឌព្រៃសហគមន៍ )

៤-៣ តម្រូវការប្រើប្រាស់ធនធានធម្មជាតិប្រចាំឆ្នាំ( លទ្ធផលសិក្សាប៉ាន់ប្រមាណការប្រើប្រាស់ )

### ៥-យុទ្ធសាស្ត្រនៃការគ្រប់គ្រង

៥-១ រចនាសម្ព័ន្ធគ្រប់គ្រង

៥-២ ការបែងចែកតំបន់គ្រប់គ្រង និងប្រើប្រាស់

៥-៣ ផែនការប្រើប្រាស់ធនធានធម្មជាតិ ( ការប្រើប្រាស់ផល អនុផលព្រៃឈើ និង

ធនធានផលផល)

៥-៤ ផែនការអភិវឌ្ឍន៍(កសិរុក្ខកម្ម អេកូទេសចរណ៍ សុវុឌ្ឍកម្មព្រៃឈើ វារីវប្បកម្ម និងរេជបូក )

៥-៤ គោលការណ៍បែងចែកផលប្រយោជន៍

៥-៥ គោលការណ៍ស្វែងរកថវិកា និងការគ្រប់គ្រង

## ៦-ផែនការអនុវត្តប្រចាំឆ្នាំ និងការអភិវឌ្ឍន៍

៦-១ ផែនការសកម្មភាពសំខាន់ៗរយៈពេល៥ឆ្នាំ

- តារាងសកម្មភាពអនុវត្តឆ្នាំទី១
- តារាងសកម្មភាពអនុវត្តឆ្នាំទី២
- តារាងសកម្មភាពអនុវត្តឆ្នាំទី៣
- តារាងសកម្មភាពអនុវត្តឆ្នាំទី៤
- តារាងសកម្មភាពអនុវត្តឆ្នាំទី៥

៦-២ យន្តការត្រួតពិនិត្យ វាយតម្លៃនិងការធ្វើរបាយការណ៍

## ៧-ឧបសម្ព័ន្ធ

- ផែនទីបែងចែកតំបន់គ្រប់គ្រងនិងប្រើប្រាស់ (មាននិយាមការ និងមាត្រដ្ឋាន ច្បាស់លាស់)
- តារាងលទ្ធផលសារពើភ័ណ្ឌព្រៃសហគមន៍
- តារាងលទ្ធផលប៉ាន់ប្រមាណផលនេសាទប្រចាំឆ្នាំ
- តារាងលទ្ធផលប៉ាន់ប្រមាណពីការប្រើប្រាស់អនុផលព្រៃឈើ
- បញ្ជីឈ្មោះសមាជិកសហគមន៍ដែលចូលរួមធ្វើផែនការគ្រប់គ្រង
- បញ្ជីឈ្មោះអ្នកពាក់ព័ន្ធដែលចូលរួមពិគ្រោះយោបល់លើសេចក្តីព្រាងផែនការ គ្រប់គ្រង

**ឧបសម្ព័ន្ធទី៥ ៖ ទម្រង់គំរូកិច្ចព្រមព្រៀង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងស្តីពី
# ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

# រវាង

# អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
# នៃក្រសួងបរិស្ថាន

# និង

# សហគមន៍តំបន់ការពារធម្មជាតិ................................................

ដែលស្ថិតនៅក្នុងឧទ្យានជាតិ........./ដែនជម្រកសត្វព្រៃ...........................មានទីតាំង
នៅភូមិ...............ឃុំ/សង្កាត់............... ស្រុក/ក្រុង............. ខេត្ត............

ធ្វើនៅ.............ថ្ងៃទី.........ខែ........ឆ្នាំ២០......

## I. មុខ្យកថានៃកិច្ចព្រមព្រៀង

១- យោង:

- ព្រះរាជក្រមលេខ នស / រកម /០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- ព្រះរាជក្រមលេខ នស / រកម /០២០៨/ ០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- ព្រះរាជក្រិត្យលេខ នស / រកម /១២៩៦-៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលបានឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៥អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- ប្រកាសស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ................................ លេខ....ប្រ.កប.ស្ក ចុះថ្ងៃទី......... ខែ.......... ឆ្នាំ២០.... របស់ក្រសួងបរិស្ថាន។

២- រាជរដ្ឋាភិបាលកម្ពុជាមានទិសដៅពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ តាមរយៈការចូលរួមពីសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅក្នុងឬក្បែរតំបន់ការពារធម្មជាតិសំដៅធានាបាននូវលំនឹងធម្មជាតិ និងឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋានប្រកបដោយនិរន្តរភាព។

៣- ព្រៃសហគមន៍តំបន់ការពារធម្មជាតិ គឺជាសម្បត្តិសាធារណៈរបស់រដ្ឋ ដែលរាជរដ្ឋាភិបាលទទួលស្គាល់សិទ្ធិចូលរួមគ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

៤- ក្រសួងបរិស្ថាន ផ្តល់ជូនសហគមន៍មូលដ្ឋានចូលរួមគ្រប់គ្រងនៅក្នុងតំបន់ប្រើប្រាស់ប្រកបដោយនិរន្តរភាពតាមប្រកាសលេខ........ចុះថ្ងៃទី.........ខែ.........ឆ្នាំ...ដែលមានផ្ទៃដីទំហំ................ហិកតាដល់សហគមន៍តំបន់ការពារធម្មជាតិ.........ស្ថិតក្នុងភូមិ........... ឃុំ/សង្កាត់..............ស្រុក/ក្រុង.........ខេត្ត............។

៥-សហគមន៍តំបន់ការពារធម្មជាតិ...................... ត្រូវមានសុច្ឆន្ទៈ និងសេចក្តីស្មោះត្រង់ក្នុងការចូលរួមគ្រប់គ្រងធនធានធម្មជាតិ ដោយអនុវត្តតាមលក្ខន្តិកៈ និងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ............................. ស្របតាមច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ ។

## II. លក្ខខណ្ឌ និងអាណត្តិនៃកិច្ចព្រមព្រៀង

១-កិច្ចព្រមព្រៀងស្តីពី ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិមានប្រសិទ្ធភាព និងចូលជាធរមានស្របតាមល័ក្ខខ័ណ្ឌដូចខាងក្រោម៖

ក- គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ............ត្រូវបានបង្កើតឡើងស្របតាមនីតិវិធីនិងមានដីកា សម្រេចទទួលស្គាល់លេខ.........ចុះថ្ងៃទី......... ខែ....... ឆ្នាំ២០.... ពីមេឃុំ/ចៅសង្កាត់។

ខ- សហគមន៍តំបន់ការពារធម្មជាតិ..................បានកំណត់ទីតាំងព្រំប្រទល់ច្បាស់លាស់និងមានផែនទី និយាមកាត្រឹមត្រូវ តាមប្រកាសលេខ ........... ប្រ.កប.ស្ក ចុះថ្ងៃទី....... ខែ........ ឆ្នាំ២០.....របស់ក្រសួងបរិស្ថាន។

គ- មានបញ្ជីឈ្មោះសុំចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ........។

ឃ-មានលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ................ដែលបានរៀបចំឡើងស្របតាមប្រកាសស្តីពីគោលការណ៍ណែនាំពីនីតិវិធី និងដំណើររៀបចំសហគមន៍តំបន់ការពារធម្មជាតិ។

ង- ភាគីអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ....................បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងមានសាក្សីដឹងឮពី មេឃុំ/ចៅសង្កាត់។

២-កិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិ..............មានសុពលភាពក្នុងរយៈពេលដប់ប្រាំ(១៥)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាដោយភាគីទាំងពីរ។

៣-កិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិ......................អាចបន្តបានដោយឈរលើលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃពី អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងមានកិច្ចសហការពីអាជ្ញាធរដែនដី។

៤-ក្នុងករណី មានការផ្លាស់ប្តូរលិខិតបទដ្ឋានច្បាប់ ឬតម្រូវការចាំបាច់ណាមួយដែលជះឥទ្ធិពលដល់ការអនុវត្តកិច្ចព្រមព្រៀងរវាងគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ....និងអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អាចធ្វើការកែសម្រួលតាមការឯកភាពគ្នារវាងភាគីទាំងពីរ។

## III. សិទ្ធិ និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ.................................................

១-រៀបចំ និងអនុវត្តផែនការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់ព្រៃសហគមន៍ ដែលក្រសួងបរិស្ថានបានផ្តល់ឱ្យលើទំហំផ្ទៃដី ដូចមានផែនទីក្នុងឧបសម្ព័ន្ធទី១នៃកិច្ចព្រមព្រៀងនេះ។

២-មានសិទ្ធិសម្រេច និងចាត់វិធានការ ស្របតាមលក្ខន្តិកៈសហគមន៍ដើម្បីការពារធនធានធម្មជាតិ និងទប់ស្កាត់បទល្មើសនានាដែលបង្កឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ព្រមទាំងជីវភាពរស់នៅរបស់សមាជិកសហគមន៍តំបន់ការពារធម្មជាតិ..........................។

៣-មានសិទ្ធិផ្តល់ព័ត៌មាន និងសហការទប់ស្កាត់បទល្មើសក្នុងឧទ្យានជាតិ................/ដែនជម្រកសត្វព្រៃ...........។

៤-មានសិទ្ធិអនុញ្ញាតឱ្យសមាជិកសហគមន៍ដកហូត និងប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណីស្របតាមលក្ខន្តិកៈ និងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ...។

៥-រៀបចំ និងកែលម្អរទីតាំងដែលមានសក្តានុពលអេកូទេសចរណ៍ ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់សមាជិកសហគមន៍តំបន់ការពារធម្មជាតិ...............។

៦-មានសិទ្ធិកែច្នៃអនុផលព្រៃឈើ ដែលមិនធ្វើឱ្យប៉ះពាល់ដល់តម្លៃជីវៈចម្រុះក្នុងតំបន់ដើម្បីបង្កើនប្រាក់ចំណូលក្នុងសហគមន៍។

៧-បែងចែកផលប្រយោជន៍ដោយឈរលើមូលដ្ឋាន តម្លាភាព និងសមធម៌ ដល់សមាជិកសហគមន៍តំបន់ការពារធម្មជាតិ..............។

៨-ទទួលខុសត្រូវចំពោះទង្វើល្មើសធ្ងន់ធ្ងរដែលបង្ករឱ្យខូចខាតដល់ធនធានធម្មជាតិនៅក្នុងព្រៃសហគមន៍តំបន់ការពារធម្មជាតិ.............។

៩-ត្រូវទទួលពិន័យ ឬដាក់ទណ្ឌកម្មស្របទៅតាមច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ក្នុងករណីប្រព្រឹត្តបទល្មើស ឬមានការឃុបឃិតជាមួយជនល្មើស។

១០-កត់ត្រាច្បាស់លាស់ពីការដកហូត និងប្រើប្រាស់ធនធានធម្មជាតិរបស់សមាជិកសហគមន៍តំបន់ការពារធម្មជាតិ............និងធ្វើរបាយការណ៍ពីសកម្មភាពភាពរីកចម្រើនព្រមទាំងបញ្ហាផ្សេងៗដែលសហគមន៍បានជួបប្រទះក្នុងពេលអនុវត្ត ជូននាយកឧទ្យានជាតិ/ដែនជម្រកសត្វព្រៃ......... មន្ទីរបរិស្ថានខេត្ត..........ជារៀងរាល់ ០៣ខែម្តង ចម្លងជូនក្រុមប្រឹក្សាឃុំ និងនាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ។

## IV. សិទ្ធិ និងការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ

១-ផ្តល់នូវការជួយសម្របសម្រួលក្នុងការរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ...................................។

២-ពង្រឹងសមត្ថភាពដល់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ...................

តាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងណែនាំការអនុវត្តន៍ផ្ទាល់។

៣-ទំនាក់ទំនងរកគម្រោង និងអង្គការដៃគូ ដើម្បីជួយអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ..................................។

៤-ផ្តល់នូវកិច្ចសហការទប់ស្កាត់បទល្មើស និងដោះស្រាយបញ្ហា ឆ្លើយតបទៅតាមសំណើររបស់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ.............។

៥-ជួយរៀបចំអត្ថបទផ្សព្វផ្សាយ និងទំនាក់ទំនងភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដើម្បីចូលទៅទស្សនាសហគមន៍តំបន់ការពារធម្មជាតិ................។

៦-អប់រំ និងផ្សព្វផ្សាយពីលិខិតបទដ្ឋាននានា ដែលទាក់ទងទៅនឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ...........................។

៧-ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់កែលម្អរទៅលើសកម្មភាពអនុវត្តន៍របស់សហគមន៍តំបន់ការពារធម្មជាតិ..........................។

## V.គោលការណ៍ដកហូត និងប្រើប្រាស់ធនធានធម្មជាតិ

១-ការដកហូតធនធានធម្មជាតិអាចប្រព្រឹត្តទៅបានស្របទៅតាមច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ។

២-សមាជិកសហគមន៍តំបន់ការពារធម្មជាតិ.........ទាំងអស់អាចប្រមូលនិងប្រើប្រាស់ធនធានធម្មជាតិបានជាលក្ខណៈប្រពៃណី។

៣-សហគមន៍តំបន់ការពារធម្មជាតិ....................អាចប្រមូលអនុផលព្រៃឈើ ឬផលនៃសាទនៅក្នុងព្រៃសហគមន៍ សម្រាប់កែឆ្នៃជាលក្ខណៈគ្រួសារ ស្របទៅតាមផែនការគ្រប់គ្រងរបស់សហគមន៍ ដែលមិនធ្វើឱ្យបាត់បង់ធនធានធម្មជាតិ។

៤-ការប្រមូលអនុផលព្រៃឈើ ត្រូវស្របតាមលក្ខន្តិកៈរបស់សហគមន៍ តំបន់ការពារធម្មជាតិ...............។

៥-សមាជិកសហគមន៍តំបន់ការពារធម្មជាតិ.................មិនអាចដកហូតផលព្រៃឈើក្នុងគោលបំណងពាណិជ្ជកម្ម ដែលធ្វើឱ្យប៉ះពាល់ដល់ជីវៈចម្រុះនៅក្នុងតំបន់ព្រៃសហគមន៍។

៦-ការដកហូតផលព្រៃឈើ សម្រាប់បម្រើផលប្រយោជន៍នៅក្នុងសហគមន៍ ត្រូវមានការឯកភាពពីសមាជិកសហគមន៍ភាគច្រើន និងមានការអនុញ្ញាតពី នាយកឧទ្យានជាតិ/ដែនជម្រកសត្វព្រៃ......................ស្របទៅតាមផែនការ គ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ។

## VI. គោលការណ៍ថែរក្សា និងអភិរក្សធម្មជាតិ

១-សមាជិកសហគមន៍តំបន់ការពារធម្មជាតិ.........ហាមដាច់ខាតការចេញចូលនៅក្នុងតំបន់ស្នូល នៃឧទ្យានជាតិ/ដែនជម្រកសត្វព្រៃ................។

២-សមាជិកសហគមន៍តំបន់ការពារធម្មជាតិ..................អាចប្រមូលអនុផលព្រៃឈើនៅក្នុងតំបន់អភិរក្សនៃឧទ្យានជាតិ/ដែនសត្វព្រៃ....................ដោយសុំការអនុញ្ញាតពីនាយកឧទ្យានជាតិ/ដែនជម្រកសត្វព្រៃ.............តាមរយៈប្រធានស្នាក់ការតំបន់ការពារធម្មជាតិ ដែលនៅជិតបំផុត។

៣-សមាជិកសហគមន៍តំបន់ការពារធម្មជាតិ...........ត្រូវថែរក្សាការពារប្រភេទសត្វនិងរុក្ខជាតិដែលមានដោយកម្រឬជាប្រភេទសត្វ និងរុក្ខជាតិ ដែលមានលក្ខណៈពិសេសក្នុងតំបន់។

៤-សហគមន៍តំបន់ការពារធម្មជាតិ................ត្រូវគ្រប់គ្រងកាកសំណល់ឱ្យបានត្រឹមត្រូវជៀសវាងប៉ះពាល់ដល់ធនធានធម្មជាតិ ប្រភពទឹក សត្វ និងរុក្ខជាតិ។

## VII.យន្តការត្រួតពិនិត្យ និងវាយតម្លៃ

១-អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងនាយកឧទ្យានជាតិ/ដែលជម្រកសត្វព្រៃ.........មានសិទ្ធិត្រួតពិនិត្យរាល់ដំណើរការអនុវត្តន៍របស់សហគមន៍តំបន់ការពារធម្មជាតិ............................។

២-សហគមន៍តំបន់ការពារធម្មជាតិ...........ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់នាយកឧទ្យានជាតិ/ដែនជម្រកសត្វព្រៃ.............ក្នុងករណីការត្រួតពិនិត្យឃើញមានភាពខ្វះចន្លោះ។

៣-ការត្រួតពិនិត្យនិងវាយតម្លៃត្រូវធ្វើឡើងដោយមានការចូលរួមពីសមាជិកសហគមន៍នាយកឧទ្យាជាតិ/ដែនជម្រកសត្វព្រៃ................និងក្រុមប្រឹក្សាឃុំ................។

## VIII. យន្តការដោះស្រាយទំនាស់

១-ក្នុងករណីគណៈកម្មការសហគមន៍បំពានលើកិច្ចព្រមព្រៀង ត្រូវដោះស្រាយដូចខាងក្រោមៈ

**ក**-ត្រូវទទួលការពិន័យឬទណ្ឌកម្មស្របទៅតាមទោស បញ្ញត្តិនៃច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ។

**ខ**-ក្រសួងបរិស្ថាន សម្រេចព្យួរ ឬប្រកាសលុបកិច្ចព្រមព្រៀង ក្នុងករណីមានការរំលោភបំពានពីសហគមន៍តំបន់ការពារធម្មជាតិ...............ដោយចេតនា។

២-ក្នុងករណី អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ បំពានលើកិច្ចព្រមព្រៀងត្រូវដោះស្រាយ ដូចខាងក្រោមៈ

**ក**-គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ..................ត្រូវធ្វើពាក្យជាលាយល័ក្ខអក្សរដាក់ជូនក្រសួងបរិស្ថានជួយសម្របសម្រួលដោះស្រាយ។

ខ-ក្នុងករណីក្រសួងបរិស្ថានមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិត្រូវធ្វើពាក្យបណ្ដឹងទៅតុលាការតាមនិតិវិធីច្បាប់។

## IX.**ប្រធានស័ក្ក**

**១-ចាត់ទុកថាជាប្រធានស័ក្កលុះត្រាតែមានលក្ខណៈដូចខាងក្រោម៖**

- មានសកម្មភាពសង្គ្រាម
- គ្រោះមហន្តរាយធម្មជាតិ។

ក្នុងករណីមានប្រធានស័ក្កណាមួយកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការគ្រប់គ្រងរបស់សហគមន៍ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ........................ត្រូវជូនដំណឹងជាបន្ទាន់ទៅ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន តាមរយៈនាយកឧទ្យានជាតិ...../ដែនជម្រកសត្វព្រៃ.................ហើយភាគីទាំងពីរមិនមានទទួលខុសត្រូវទៅលើការបាត់បង់ ឬខូចខាតផលប្រយោជន៍របស់ភាគីណាមួយឡើយ។

**២-មិនត្រូវបានចាត់ទុកជាប្រធានស័ក្កមានដូចខាងក្រោមៈ**

- បញ្ហាសេដ្ឋកិច្ចឬទីផ្សារដែលជះឥទ្ធិពលដល់ដំណើរការរបស់សហគមន៍
- ការមិនអនុវត្តតួនាទីនិងភារកិច្ចរបស់គណៈកម្មការសហគមន៍ដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្តការងារសហគមន៍តំបន់ការពារធម្មជាតិ...................។

## X.**លក្ខខណ្ឌផ្សេងៗ**

១-កិច្ចព្រមព្រៀងនេះត្រូវបានរៀបចំជាភាសាខ្មែរ និងប្រើប្រាស់ជាមូលដ្ឋានសំដៅធ្វើឱ្យប្រសើរឡើងក្នុងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ................។

២-កិច្ចព្រមព្រៀងនេះ ត្រូវបានរៀបចំឡើងចំនួន០៦ច្បាប់ សម្រាប់តម្កល់នៅសហគមន៍តំបន់ការពារធម្មជាតិ........០១ច្បាប់
សាលាឃុំ/សង្កាត់.......០១ច្បាប់
ស្នាក់ការឧទ្យានជាតិ........../ដែនជម្រកសត្វព្រៃ......០១ច្បាប់ មន្ទីរបរិស្ថាន០១ច្បាប់
នាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ០១ច្បាប់
និងអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិចំនួន០១ច្បាប់។

**ធ្វើនៅ..............ថ្ងៃទី......ខែ.......ឆ្នាំ២០.....**

| | |
|---|---|
| **ហត្ថលេខា** | **ហត្ថលេខា** |
| **អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ** | **គណៈកម្មការសហគមន៍តំបន់ ការពារធម្មជាតិ**.............. |

**ហត្ថលេខា**

**សាក្សី**
**តំណាងក្រសួងបរិស្ថាន**
.......................................

**សាក្សី**
**មេឃុំ/ចៅសង្កាត់**
...........................................

## ឧបសម្ព័ន្ធទី៦ ៖ ទម្រង់គំរូ ក្របខណ្ឌសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ

គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ត្រូវប្រើប្រាស់លក្ខខណ្ឌទាំងបួនសម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃ ដោយអាចពិចារណានិងកែសម្រួលលើលក្ខណៈវិនិច្ឆ័យ និងសូចនាករ ដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែងរបស់សហគមន៍តំបន់ការពារធម្មជាតិនីមួយៗ។ ខាងក្រោមនេះគឺ ជាឧទាហរណ៍មួយចំនួនប៉ុណ្ណោះ។

## លក្ខខណ្ឌទី ១ ៖ ធនធានធម្មជាតិត្រូវបានថែរក្សា

| ល.រ | លក្ខណៈវិនិច្ឆ័យ | សូចនាករ |
|---|---|---|
| ១ | មានការកំណត់តំបន់គ្រប់គ្រង និងប្រើប្រាស់ច្បាស់លាស់ | - មានការបែងចែកតំបន់ប្រើប្រាស់<br>- មានព្រំប្រទល់ និងស្លាកសញ្ញា បញ្ជាក់ពីតំបន់នីមួយៗ<br>- មានដាក់ស្លាកសញ្ញាហាមឃាត់<br>- មានផែនទីមាត្រដ្ឋាន<br>- មានបង្គោលព្រំប្រទល់<br>- មានបឹងអភិរក្សពូជត្រី....។ |
| ២ | ជីវៈចម្រុះត្រូវបានថែរក្សានិងការពារ | - មានការដាំឈើឡើងវិញ<br>- សត្វព្រៃមានការកើនឡើង<br>- ប្រភេទរុក្ខជាតិនិងសត្វកម្រមានការកើនឡើង<br>- ចំនួននៃការបបរបាញ់ និងចាប់សត្វថយចុះ<br>- មានដំណុះឈើឡើងវិញ<br>- មានមធ្យោបាយការពារភ្លើងព្រៃសហគមន៍។ |
| ៣ | ធនធានធម្មជាតិក្នុងតំបន់គ្រប់គ្រងរបស់សហគមន៍ត្រូវបានថែរក្សា និងកែលម្អរ | - ការធ្វើសុវ្ឌ្ឍិកម្មព្រៃឈើ<br>- មានការកំណត់ប្រភេទឈើមេពូជ<br>- ផល-អនុផលព្រៃឈើមានការកើនឡើង<br>- ការដុតព្រៃត្រូវបានបញ្ឈប់<br>- ការកាប់រានព្រៃត្រូវបានទប់ស្កាត់<br>- ការកាប់ឈើខុសច្បាប់ត្រូវបានទប់ស្កាត់<br>- ផលនេសាទមានការកើនឡើងវិញ |

| | | |
|---|---|---|
| | | - រក្សាបានគម្របព្រៃសហគមន៍ |
| ៤ | ការប្រើប្រាស់ឧបករណ៍ និងការដេកហូតធនធានធម្មជាតិមានលក្ខណៈសមស្រប | - ការប្រើប្រាស់ឧបករណ៍ខុសច្បាប់ត្រូវបានលប់បំបាត់<br>- គ្មានការនេសាទជាលក្ខណៈអជីវកម្មនៅរដូវបិទនេសាទ<br>- គ្មានការកាប់រលំដើមក្នុងការប្រមូលអនុផលព្រៃឈើ។ |

**លក្ខខណ្ឌទី ២ ៖ សុខមាលភាពសមាជិកសហគមន៍ត្រូវបានធ្វើឱ្យប្រសើរឡើង**

| ល.រ | លក្ខណៈវិនិច្ឆ័យ | សូចនាករ |
|---|---|---|
| ១ | សមាជិកសហគមន៍ទទួលបានការប្រើប្រាស់ធនធានធម្មជាតិ | - សមាជិកសហគមន៍បានប្រើប្រាស់អនុផលព្រៃឈើ( បន្លែព្រៃ ផ្លែឈើព្រៃ ជ័រ វល្លិ៍ ផ្តៅ ឬស្សី...)<br>- សមាជិកសហគមន៍ទទួលបានផលឈើសម្រាប់ការជួសជុល ឬសាងសង់លំនៅដ្ឋាន និងសម្ភារៈ ប្រើប្រាស់ផ្សេងៗ<br>- សមាជិកសហគមន៍បានប្រើប្រាស់រុក្ខជាតិឱសថ សម្រាប់ការ ថែរក្សាសុខភាព<br>- សមាជិកសហគមន៍បានធ្វើការនេសាទសម្រាប់ទ្រទ្រង់ជីវភាព។ |
| ២ | ធនធានធម្មជាតិក្នុងតំបន់សហគមន៍បានរួមចំណែកផ្តល់ប្រាក់ចំណូលសម្រាប់ទ្រទ្រង់ជីវភាព | - សមាជិកសហគមន៍បានប្រាក់ចំណូលពីអនុផលព្រៃឈើ<br>- សមាជិកសហគមន៍បានប្រាក់ចំណូលពីសេវាទេសចរណ៍ធម្មជាតិ<br>- សមាជិកសហគមន៍បានប្រាក់ចំណូលពីការនេសាទក្នុងតំបន់សហគមន៍។ |
| ៣ | ព្រៃសហគមន៍បានរួមចំណែកជួយដល់ផ្នែកកសិកម្ម | - សមាជិកសហគមន៍បានប្រើប្រាស់ផលអនុផលព្រៃឈើសម្រាប់ការងារកសិកម្ម<br>- ស្រែចំការក្បែរព្រៃសហគមន៍ រក្សាបានដី |

| | | |
|---|---|---|
| | | ដាតិដីនិងទទួលបានទិន្នផលប្រសើរឡើង<br>- ព្រៃសហគមន៍បានរក្សាប្រភពទឹកសម្រាប់ការស្រោចស្រព<br>- ព្រៃសហគមន៍ជួយផ្តល់នូវចំណីសម្រាប់ការចិញ្ចឹមសត្វ ។ |
| ៤ | សមាជិកសហគមន៍មានឱកាសទទួលបានមុខរបរបំពេញបន្ថែមផ្សេងៗ | - មានការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ<br>- សមាជិកសហគមន៍ចេះកែច្នៃអនុផលព្រៃឈើ<br>- មានការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ<br>- មានការដាំបន្លែ និងឈើហូបផ្លែ។ |

## លក្ខខណ្ឌទី ៣ ៖ សុខុមាលភាពសហគមន៍ត្រូវបានធានា

| ល.រ | លក្ខណៈវិនិច្ឆ័យ | សូចនាករ |
|---|---|---|
| ១ | ប្រព័ន្ធគ្រប់គ្រងសហគមន៍បង្កើតឡើងដោយមានការចូលរួមពីសមាជិក | - ចំនួនសមាជិកសហគមន៍ បានរៀបចំឡើងតាមការស្ម័គ្រចិត្ត<br>- គណៈកម្មការត្រូវបានជ្រើសរើសតាមការបោះឆ្នោតប្រកប ដោយតម្លាភាព និងសមភាពរវាងបុរស ស្ត្រី<br>- លក្ខន្តិកៈត្រូវបានធ្វើឡើងដោយសហគមន៍មូលដ្ឋាន និងមានចែងច្បាស់ពី សិទ្ធិ តួនាទី និងការទទួលខុសត្រូវ<br>- សមាជិកសហគមន៍បានចូលរួមរៀបចំផែនការគ្រប់គ្រងសហគមន៍។ |
| ២ | មានយន្តការគ្រប់គ្រងនិងការដោះស្រាយទំនាស់ប្រកបដោយប្រសិទ្ធភាព | - សមាជិកបានចូលរួមក្នុងការត្រួតពិនិត្យនិងវាយតម្លៃលើការគ្រប់គ្រងព្រៃសហគមន៍<br>- មានយន្តការត្រួតពិនិត្យក្នុងការដកហូត និងប្រើប្រាស់ផល អនុផលព្រៃឈើ<br>- សកម្មភាពត្រួតពិនិត្យត្រូវបានអនុវត្តទៅតាមផែនការគ្រប់គ្រងច្បាស់លាស់ |

| | | |
|---|---|---|
| | | - លក្ខន្តិកៈត្រូវបានសមាជិកទាំងអស់គោរព និងអនុវត្ត<br>- ការដេកហូតផល អនុផលព្រៃឈើមាន ការកត់ត្រាច្បាស់លាស់ និងផ្សព្វផ្សាយ ដល់សមាជិក។ |
| ៣ | គណៈកម្មការមានសមត្ថភាពដឹកនាំ | - ទំនាស់នៃការប្រើប្រាស់ធនធានក្នុង សហគមន៍ត្រូវបានដោះ ស្រាយដោយ គណៈកម្មការសហគមន៍<br>- គ្រប់ពេលប្រជុំមានសមាជិកសហគមន៍ចូល រួមលើសពី ៦០%<br>- មានសមាជិកសហគមន៍ចូលរួមយាម ល្បាតជាប្រចាំ<br>- សមាជិកសហគមន៍បានផ្តល់ព័ត៌មានពី បទល្មើស<br>- ការទប់ស្កាត់បទល្មើសបានទាន់ពេលវេលា<br>- ការចែករំលែកព័ត៌មាន និងគ្រប់គ្រង ឯកសាច្បាស់លាស់។ |
| ៤ | តម្លាភាពក្នុងការគ្រប់គ្រង | - មានបញ្ជីគណនេយ្យ និងការកត់ត្រាច្បាស់ លាស់<br>- មានរបាយការណ៍ចំណូលចំណាយ<br>- មានការបង្ហាញពីថវិកាចំណូលចំណាយដល់ សមាជិកសហគមន៍ |

## លក្ខខណ្ឌទី ៤ ៖ ការគាំទ្រពីមជ្ឈដ្ឋានខាងក្រៅ

| ល.រ | លក្ខណៈវិនិច្ឆ័យ | សូចនាករ |
|---|---|---|
| ១ | អ្នកពាក់ពន្ធ័ចូលរួម និងគាំទ្រដល់ ការគ្រប់គ្រងរបស់សហគមន៍ | - អ្នកភូមិជិតខាងគោរពទៅតាមលក្ខន្តិកៈ និង ផែនការគ្រប់គ្រង របស់សហគមន៍<br>- សកម្មភាពល្មើស បំពាន ពីអ្នកខាងក្រៅត្រូវ បានលប់បំបាត់ |

| | | |
|---|---|---|
| | | - ស្ថាប័នជំនាញ ឬអង្គការក្រៅរដ្ឋាភិបាល ជួយឧបត្ថម្ភបច្ចេកទេសដល់សហគមន៍ក្នុងការគ្រប់គ្រង<br>- មានការចូលរួមអន្តរាគមន៍ពីអាជ្ញាធរដែនដី និងស្ថាប័នជំនាញលើការដោះស្រាយទំនាស់<br>- ក្រុមប្រឹក្សាឃុំចូលរួមត្រួតពិនិត្យ និងវាយតម្លៃ។ |
| ២ | គោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍសហគមន៍ | - មានច្បាប់ និងលិខិតបទដ្ឋានគាំទ្រដល់សិទ្ធិ និងផលប្រយោជន៍របស់សហគមន៍តំបន់ការពារធម្មជាតិ<br>- សកម្មភាពសហគមន៍ត្រូវបានរួមបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>- សហគមន៍ទទួលបានការលើកទឹកចិត្តពីស្ថាប័នជំនាញ និងអាជ្ញាធរ<br>- យន្តការដោះស្រាយទំនាស់ក្នុងសហគមន៍ត្រូវបានចូលរួមគាំទ្រអនុវត្តពីស្ថាប័នជំនាញ និងអាជ្ញាធរដែនដី។ |
| ៣ | មានការអប់រំក្នុង និងក្រៅប្រពន្ធ័ ដែលគាំទ្រដល់ការចូលរួមគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍ | - ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាពត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំ<br>- មានការផ្សព្វផ្សាយស្តីពីសកម្មភាពគ្រប់គ្រងរបស់សហគមន៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ<br>- បទដ្ឋានច្បាប់ និងឯកសារដែលពាក់ពន្ធ័ការគ្រប់គ្រងសហគមន៍ត្រូវបានផ្សព្វផ្សាយដល់មូលដ្ឋាន<br>- មានវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រប់គ្រងដល់សហគមន៍ ។ |
| ៤ | ការជួយគាំទ្រលើទីផ្សារលក់ផលិតផល | - មានដៃគូរនៅលើទីផ្សារ<br>- មានកិច្ចសន្យាច្បាស់លាស់ជាមួយដៃគូរ<br>- មានការចែកផលប្រយោជន៍ច្បាស់លាស់<br>- មានលខិតអនុញ្ញាតដឹកជញ្ជូនផលិតផលរបស់សហគមន៍។ |

## ឧបសម្ព័ន្ធទី ៧ ៖ ទម្រង់គំរូរបាយការណ៍សម្រាប់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមគោរពជូន**
**លោកនាយក**..............................................

**កម្មវត្ថុ**: របាយការណ៍ប្រចាំត្រីមាសទី........ឆ្នាំ២០.........របស់សហគមន៍តំបន់ការពារធម្មជាតិ..................................។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូននាយក................ មេត្តាជ្រាបថាក្នុងត្រីមាសទី....... ឆ្នាំ២០......... សហគមន៍តំបន់ការពារធម្មជាតិ................. បានអនុវត្តសកម្មភាពនិងទទួលបានលទ្ធផលដូចខាងក្រោម៖

ទី១....................................................លទ្ធផល.................................
....................................................................................................................
..................................................................................................................

ទី២....................................................លទ្ធផល...............................
....................................................................................................................
..................................................................................................................។

ទី៣.......................................................លទ្ធផល..........................
....................................................................................................................
..................................................................................................................។

**បញ្ហាជួបប្រទះ**:..........................................................................
....................................................................................................................
..................................................................................................................។

**សំណូមពរ**..........................................................................................
....................................................................................................................
..................................................................................................................។

**ទិសដៅអនុវត្តបន្ត**......................................................................................
..........................................................................................................................................
..........................................................................................................................................
.......................................................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកនាយក មេត្តាជ្រាបជារបាយការណ៍។

សូមលោកនាយកទទួលនូវការគោរពអំពីខ្ញុំ៕

..........ថ្ងៃទី...........ខែ......ឆ្នាំ២០.........

**អ្នកធ្វើរបាយការណ៍**

**<u>ចម្លងជូន</u>**

សាលាស្រុក/ក្រុង......................

សាលាឃុំ/សង្កាត់......................